…សៀវភៅសិក្សា

ព្រលឹងខ្មែរ

# ភាសិត សម្រាំង

អធិប្បាយតាមលំដាប់អក្សរ

៣

…ាគារ ប៊ុក·ណាប់ ភ្នំពេញ

R-4 5-9-55
Tome III
C.807
B.135-1649 3-4

# ភាសិតសម្រាំង

## ភាគ ៣

### អធិប្បាយតាមលំដាប់អក្សរ

ការផ្សាយរបស់

បណ្ណាគារ ប៊ុក-តាង

លេខ ១០ រុក្ខវិថីអាល់បែរត៍ទី-១ ភ្នំពេញ

ពុ.ស. ២៤៩៨, គ.ស. ១៩៥៥

( ទុកសិទ្ធិ )

R. 688-5-55

ខេត្រ - ខែម

អធិការបឋមសិក្សា

# សេចក្តីណែនាំ

# គ្រូបង្រៀននៅសាលាបឋមសិក្សា

រោងពុម្ព ហង្ស .រី វិថីអូហ៊ុយេរលេខ ៧៧ ភ្នំពេញ

ទុកសិទ្ធិ

ព.ស. ២៤៩៨ គ.ស. ១៩៥៥

# របៀបរៀបចំកន្លែងរៀន – វិន័យរបស់សិស្ស

## អំពីការបំបែកសិស្សឲ្យទៅតាមថ្នាក់

នៅក្នុងសាលានីមួយៗ គេបំបែកសិស្សឲ្យទៅនៅតាមថ្នាក់ :

កុមារដ្ឋាន

បរិវុឌ្ឍនដ្ឋាន

អាទិកដ្ឋាន

មធ្យមដ្ឋាន ឆ្នាំទីមួយ

មធ្យមដ្ឋាន ឆ្នាំទីពីរ

ឧត្តមដ្ឋាន

តាមចំណេះរបស់វា ដែលគេបានស្គាល់ ដោយគេបានឲ្យវាប្រឡងកាល ពីចុងឆ្នាំសិក្សា ដែលកន្លងទៅហើយនោះ ។

## អំពីការរៀបចំសិស្សក្នុងថ្នាក់

ក្នុងថ្នាក់នីមួយៗតាមធម្មតា គេឲ្យសិស្សតូចៗអង្គុយខាងមុខ សិស្សធំៗខាងក្រោយ ឥតមានគិតថា សិស្សនេះពូកែ សិស្សនោះខ្សោយ តែគេមិនត្រូវភ្លេចថា បើមានសិស្សណាត្រចៀកធ្ងន់ ឬភ្នែកអន់ គេទុក

ឲ្យវាអង្គុយខាងមុខដែរ តែគេឲ្យវាអង្គុយនៅចុង ១ គុ ដើម្បីកុំឲ្យបាំងសិស្សដែលអង្គុយខាងក្រោយ ។ ម្យ៉ាងទៀត គេមិនឲ្យសិស្សរបុលរប៉ូចអង្គុយជិតគ្នាទេ ព្រោះវាមុខជាទីងមានឱកាសប្រឡែងគ្នាជាមិនខាន ។ បើមានសិស្សច្រើនពួក ផ្សេងៗពីគ្នា គេក៏មិនឲ្យវាអង្គុយលាយឡំគ្នាដែរ គេមិនឲ្យពួកនេះ អង្គុយក្រោយពួកនោះ គេទុកដាក់ឲ្យពួកសិស្សនីមួយ ៗ អង្គុយទមគ្នា ។ គេមិនត្រូវឲ្យសិស្សអង្គុយផ្តុំគ្នា តាមសាសន៍របស់វាទេ ។

ឯការពិនិត្យ មើលត្រៀតគទីងក្នុងនោះ គេត្រូវធ្វើនៅវេលាដែលសិស្សទើបចូលមករៀន ។

## ការណីយកិច្ចរបស់សិស្សដែលនៅក្នុងថ្នាក់

សិស្សទាំងអស់ ត្រូវថែខ្លួនប្រាណ ទីងសំលៀកបំពាក់ឲ្យបានស្អាតជានិច្ច ។ គ្រូត្រូវពិនិត្យមើលការនេះ ព្រឹក-ល្ងាច រៀងរាល់ថ្ងៃ ក្នុងវេលាដែលសិស្សឈរដំរៀបគ្នាបំរុងទីងចូលរៀន ។ ក្នុងថ្នាក់រៀននីមួយ ៗ សិស្សមិនត្រូវដើរចេញពីកន្លែងរបស់ខ្លួនឥតច្បាប់ ចោលកំទេចក្រដាស ខាក ស្តោះ ថ្លាក់តុក្អួដើងម៉ា គូរឬសរសេរលើជញ្ជាំង ។ សិស្សនីមួយ ៗ ត្រូវឲ្យចេះកោតខ្លាចគ្រូបាធ្យាយ៍ កាន់កិរិយាសុភាពរាបទាបគ្រប់វេលាចំពោះគ្រូគន ។ ក្នុងវិស្សមកាស សិស្សណាក៏ដោយ មិនត្រូវនៅក្នុងកន្លែងរៀនទេ ។

ចលនារបស់សិស្សទាំងឡាយ ចេញពីកន្លែងរៀនក្តី ទៅជំបន់ណាក្តី ចូលទៅក្នុងកន្លែងរៀនវិញក្តី ត្រូវធ្វើឲ្យមានរបៀបរៀបរយ ។

## ទណ្ឌកម្ម

គ្រូមិនត្រូវ ជាដាច់ខាត វាយសិស្សនឹងរំពាត់ ។ គ្រូណាដែលមិនធ្វើតាមបញ្ញតិខាងលើនេះ សំដែងឲ្យឃើញថា គ្រូនោះមិនប៉ុនប្រសប់ក្នុងការបង្ហាត់បង្រៀនសិស្ស ។

បើសិស្សណាប្រព្រឹត្តខុស–ឆ្គងគ្រូមានអំណាច :

ក) ឲ្យពិន្ទុអាក្រក់ ;

ខ) ដាស់តឿនដោយអនុគ្រោះ មិនបំអកឡកឡឺយ មិនបង្អាប់បន្តុះ ;

គ) ដាក់ការផ្សេងៗ ប្លែកពីការធម្មតាឲ្យធ្វើក្រៅពេលរៀន គឺឲ្យសរសេរ ២៥ ចប់ – ៥០ ចប់ – ១០០ ចប់ – ១៥០ ចប់ ។ល។ ឃ្លាណាដែលអាចញុំាងសិស្សឲ្យប្រព្រឹត្តបានប្រសើរឡើង ។

ឃ) ឯទោសដល់ទៅដេញមិនឲ្យរៀន ទោះ ៤–១០ ថ្ងៃក្តី មិនឲ្យរៀនរហូតក្តី នោះត្រូវចាងហ្វាងសាលាកាត់ទោស ដោយបានព្រមព្រៀងជាមួយនឹងគ្រូទាំងអស់ផង ។ បើមានទោសដល់បែបនេះ ចាងហ្វាងសាលា ត្រូវធ្វើសេចក្តីរាយការណ៍ ផ្ញើទៅជូនលោកអធិការ ។

# របៀបបង្រៀន

## របៀបបង្រៀនសរសេរអក្សរ

ការនេះសំខាន់ណាស់ ព្រោះអក្សរនីមួយ ៗ គេមិនមែនគ្រាន់តែគូសឲ្យកើតជាតួអក្សរនោះទេ ព្រោះមានតួអក្សរខ្លះ គេចាប់ពីក្រោមទៅលើ ខ្លះទៀតគេចាប់ពីលើចុះមកក្រោមវិញ ។

ដើម្បីនឹងបង្រៀនសរសេរតួអក្សរនីមួយ ៗ :

១) គ្រូយកតួអក្សរនោះមកបង្ហាញសិស្សទាំងអស់គ្នា ។

២) គ្រូសរសេរតួអក្សរនោះដោយច្បាស់លាស់ នៅលើក្ដារខៀនបញ្ឈរ ព្រមទាំងពន្យល់ឲ្យសព្វគ្រប់ផង ។

៣) គ្រូនាំសិស្សទាំងអស់ ឲ្យវាសនឹងអង្គុលដៃ តាមខ្យល់តួអក្សរ ដែលគ្រូទើបនឹងសរសេរបង្ហាញនៅលើក្ដារខៀនបញ្ឈរ ។

៤) ចាត់សិស្សមួយ ឬ ពីរនាក់ ឲ្យមកសរសេរតួអក្សរនោះនៅលើក្ដារខៀនបញ្ឈរ ឲ្យសិស្សទាំងអស់គ្នាមើល តើមានទាស់ខុសត្រង់ណាខ្លះ ដើម្បីឲ្យវាកែឲ្យបានសមរម្យឡើង ។

៥) ឲ្យសិស្សទាំងអស់គ្នា សរសេរតួអក្សរនោះនៅ -

ក្ដារខៀន រួចលើកបង្ហាញគ្រូ បើមានសិស្សណាសរសេរតួអក្សរនោះ មិនត្រឹមត្រូវទេ ត្រូវឲ្យវាកែឲ្យបានគួរសមឡើង ។

## របៀបបង្រៀនស្រៈ

ដំបូងបង្អស់ គេត្រូវបង្រៀនសិស្សអាន – សរសេរអក្សរ ( អ ) ពេញតួ ផ្សំនឹងស្រៈនិស្ស័យ ឲ្យចេះជាប្រាកដ ។ លុះដល់កាលណាសិស្សចេះអាន ចេះសរសេរអក្សរ ( អ ) ពេញតួ ផ្សំនឹងស្រៈនិស្ស័យហើយ គេលុបអក្សរ (អ) ពេញតួចេញ ឲ្យនៅតែស្រៈនិស្ស័យ ដើម្បីនឹងយកទៅផ្សំនឹងព្យញ្ជនៈឯទៀត ។ គេមិនត្រូវបង្រៀនអក្សរ ( អ ) ពេញតួ ផ្សំនឹងស្រៈនិស្ស័យទាំងអស់តែម្ដងទេ ។ ក្នុងមួយពេល ៗ គេបង្រៀនតែ ( អ ) នឹង ( អា ) ប៉ុណ្ណោះសិនបានហើយ តែគេនាំឲ្យសិស្សសង្កេតមើល តើ (អា) ខុសពី (អ) ត្រង់ណាខ្លះ តើគេដាក់អ្វីថែមលើ (អ) ទើបបានទៅជា (អា) ។

តពីនេះទៅ គេបង្រៀនតែ (អិ) នឹង (អី) ក៏គ្រប់គ្រាន់ហើយ គេនាំសិស្សឲ្យសង្កេតមើលតើ (អិ) នឹង (អី) ប្លែកគ្នា ពីអក្សរ (អ) មកអំពីអ្វី ។ (អិ) ប្លែកពី (អ) ដោយមានរង្វង់មួយវែងដាក់ពីលើ (អី) ប្លែកពី (អិ) ដោយមានគ្រៀសមួយនៅលើរង្វង់វែង ។

គេបង្រៀនបន្តិចម្តង ៗ ដូចបានពណ៌នាខាងលើនេះទាល់តែចប់ ។

## របៀបផ្សំព្យញ្ជនៈនឹងស្រះនិស្ស័យ

ដើម្បីបង្រៀនសិស្សឲ្យចេះផ្សំព្យញ្ជនៈនឹងស្រះនិស្ស័យ គ្រូត្រូវឲ្យមានតួអក្សរ នឹងស្រះនិស្ស័យនីមួយ ៗ សរសេរដោយច្បាស់លាស់លើក្រដាសក្រាស់មួយសន្លឹក ។ ឧបមា ដូចជាបង្រៀន (កា) (កុ) (កើ) (កេ) (កោះ) ។ ល ។ គ្រូត្រូវយកក្រដាសក្រាស់ ដែលមានតួអក្សរ (ក) ហើយនឹងក្រដាសដែលមានស្រះនិស្ស័យមកបង្ហាញ ហើយសួរសិស្សថា នេះអក្សរអ្វី? – ស្រះអ្វី? ។ គ្រូផ្សំតួអក្សរ (ក) នឹងស្រះនិស្ស័យ (ើ) ឲ្យសិស្សមើល រួចឲ្យសិស្សម្នាក់រក (កើ) ដែលគ្រូសរសេរមុនពេលចូលរៀន នៅលើក្ដារខៀនបញ្ជរ ។

គេបង្រៀន (កា) (កុ) (កេ) (កោះ) ។ ល ។ ដូចបានពន្យល់ខាងលើនេះ ។

## របៀបបង្រៀនអាននៅថ្នាក់ដំបូង

១– គ្រូចង្អុលពាក្យនីមួយ ៗ ដែលបានសរសេរទុកជាមុន នៅលើក្ដារខៀនបញ្ជរ ឲ្យសិស្សម្នាក់អាន ។ បើសិស្សនេះ

មើលមិនរួច គ្រូត្រូវឲ្យសិស្សម្នាក់ទៀតអាន ហើយឲ្យវាបំបែក ឬប្រែកប ឲ្យគូកនវាស្ដាប់ ដើម្បីឲ្យវាបានយល់ផង ។

២_ ឲ្យសិស្សមួយពួកអានព្រមគ្នា ក្នុងមួយពួក ៗ ត្រូវឲ្យមានសិស្សតែ ៥ ឬ ៦ នាក់ ដែលមានចំណេះស្មើគ្នា ។ ពួកនីមួយៗត្រូវមានឈ្មោះ ដោយយកឈ្មោះសិស្សណាដែលប្រសើរជាងគេ នៅក្នុងពួកនោះ ដូចជា “ពួកចៅសម” ។ បើចៅសមនេះប្រព្រឹត្តអំពើអ្វីដ៏មិនគប្បី ត្រូវបដិសេធឈ្មោះវាចេញ យកឈ្មោះសិស្សមួយនាក់ទៀតក្នុងហ្វូងរបស់វានោះ ដាក់ជំនួសចៅសម ។ ក្នុងកន្លែងរៀននីមួយ ៗ ឲ្យសិស្សអានតាមពួកៗ បានហើយ កុំឲ្យសិស្សទាំងអស់មើលព្រមគ្នា ព្រោះជាការនាំឲ្យថ្នាក់ដែលនៅជិតខាងគេស្ដាប់អ្វីពុំបានសោះ ។

៣_ ឲ្យសិស្សម្នាក់អានតៗគ្នា សិស្សនីមួយៗមិនត្រូវអានទាល់តែចប់ រួចឈប់ទៅទេ ត្រូវអានបានតែបន្តិច គ្រូបញ្ឈប់វា រួចចាត់សិស្សម្នាក់ទៀតឲ្យអានតទៅ លុះត្រាតែកាលណាគ្រូឲ្យឈប់ ។ គេឲ្យសិស្សអានម្នាក់ម្ដង បានពីរបីនាក់ គេឲ្យសិស្សមួយពួកអានត ។ គេត្រូវធ្វើបែបនេះ រៀងរហូតលុះអស់ពេលដែលត្រូវបង្រៀនអាន ។

# របៀបបង្រៀនអាន

## នៅថ្នាក់ អាទិកដ្ឋាន មធ្យមដ្ឋាន ឧត្តមដ្ឋាន

គ្រូត្រូវហ្វឹកហ្វឺនសិស្ស ឲ្យវាអានដូចជាវានិយាយ ទៅកាន់គូកនវា ដូចជាគេនិយាយតាមធម្មតា ។

១– គ្រូអានបទមួយបប់ ជាគំរូឲ្យសិស្សស្តាប់ តាមសេចក្តីរំលឹកខាងលើនេះ ។

២– ឲ្យសិស្សអានមួយវគ្គម្តង ៗ ព្រមទាំងពន្យល់ពាក្យណាដែលសិស្សពុំទាន់ស្គាល់ ដោយរកពាក្យដែលមានន័យប្រហែលគ្នា ឬដែលមានន័យផ្ទុយពីគ្នា ឬដោយយកគំនូរមកបង្ហាញ បើគ្មានគំនូរបស់ ឬធ្វើកិរិយាឲ្យសិស្សឃើញ ។

៣– ឲ្យសិស្សអានម្នាក់ម្តង ៗ តៗគ្នា តាមវគ្គៈ ហើយសួរបញ្ជាក់ អំពីពាក្យណាដែលបានពន្យល់រួចមកហើយ ។

៤– ឲ្យសិស្សអានបទទាំងមូល ម្នាក់ម្តង មួយពួកម្តង ៗ ព្រមទាំងសួរបញ្ជាក់សេចក្តីដែលគេអធិប្បាយ ។

៥– ឲ្យសិស្សសង្ខេបបទដែលទើបនឹងអានរួច ហើយឲ្យរកគោលសេចក្តីដែលគេអធិប្បាយ ។

# របៀបបង្រៀនពាក្យ និង ភាសា

ពាក្យដែលយកមកបង្រៀន ត្រូវជ្រើសយកពីក្នុងបទដែលបានអាន រួចមកហើយ ព្រមទាំងពាក្យណាដែលមានន័យប្រហែលគ្នា ពាក្យណាដែលមានន័យផ្ទុយពីគ្នា ។

ចំពោះពាក្យនីមួយ ៗ ដែលត្រូវបង្រៀននោះគេ :

១– ឲ្យសិស្សចេះអាន ចេះសរសេរ ដោយច្បាស់លាស់ ហើយត្រឹមត្រូវផង ;

២– ឲ្យសិស្សស្គាល់ន័យរបស់ពាក្យនីមួយ ៗ ជាប្រាកដ ដោយពន្យល់ដូចកាលបង្រៀនអាន ។

៣– ឲ្យសិស្សចេះប្រើពាក្យនីមួយ ៗ ក្នុងឃ្លាដែលគេធ្លាប់ប្រើជាធម្មតា ។ បើសិស្សរកសេចក្ដីពុំបានល្អទេ គេត្រូវជួយណែនាំ ទឹងពាក្យសួរ ៗ គេឲ្យសិស្សម្នាក់ សរសេរឃ្លាល្អ ៗ នៅលើក្ដារខៀន បញ្ជរ ដើម្បីទុកឲ្យសិស្សចម្លងដាក់ក្នុងកូនសៀវភៅរបស់វា ។ ក្នុងភាសានីមួយ ៗ គេមិនដែលយកពាក្យតែឯកឯងមកប្រើទេ គេបញ្ចេញមតិរបស់គេ ដោយសរសេរក្ដី ដោយវាចាក្ដី ជាឃ្លា ៗ ។

# របៀបបង្រៀនតែងសេចក្ដី

នៅថ្នាក់ទាប ៗ គេឲ្យសិស្សបំពេញឃ្លា ឲ្យសិស្សតែងជាឃ្លា ទីង ពាក្យដែលវាស្គាល់ ឲ្យសិស្សឆ្លើយតាមពាក្យសួរ ចំពោះលើវត្ថុណា ដែលបានបង្រៀនរួចមកហើយ ។ នៅថ្នាក់ខ្ពស់ ៗ គេឲ្យតែងជាសេចក្ដី តាមរឿងដែលគេចោទ ។

មុននឹងឲ្យសិស្សតែងសេចក្ដី គេឲ្យសិស្សអានរឿងដែលចោទនោះ គេពន្យល់ពាក្យពិបាក ៗ រួចគេនាំសិស្សឲ្យរកគោលសេចក្ដី ។

ក្នុងការតែងសេចក្ដីនីមួយ ៗ មានបីចំណែក :

១— សេចក្ដីផ្ដើម ;

២— តួសេចក្ដី ;

៣— សេចក្ដីបញ្ចប់ — យោបល់ ;

លុះរកគោលសេចក្ដីបានស្រេចហើយ គេនាំសិស្ស ដោយចោទសួរ ឲ្យអធិប្បាយមាត់ទទេ ក្នុងគោលនីមួយ ៗ ។

ចំណែកដែលពិបាកជាងគេ ដែលសិស្សភាគច្រើនរកពុំឃើញ គឺ យោបល់ ។

បើអធិប្បាយអំពីរបស់អ្វីមួយ ដូចជាដងប៉ាកកា សិស្សមិនត្រូវថ្លែងថា: "ខ្ញុំត្រូវប្រយ័ត្នមិនឲ្យបាត់ដងប៉ាកការបស់ខ្ញុំទេ ព្រោះឪពុកម្ដាយខ្ញុំ ត្រូវ

បំណាយប្រាក់ទិញដងប៉ាកកាថ្មីឲ្យខ្ញុំទៀត ” ។ គួរតែនាំសិស្ស ឲ្យបញ្ចេញសេចក្ដីដូចបែបនេះ “បើគ្មានដងប៉ាកកា តើយើងនឹងបានអ្វីយកមកសរសេរឲ្យបានស្រួល ហើយបានរហ័សផង មានតែយកស្លាបសត្វមកប្រើដូចមនុស្សជាន់ដើម ។ តើយើងនឹងទៅរកស្លាបសត្វឯណាឲ្យបានគ្រប់គ្នា ។ ចុះស្លាបសត្វនីមួយ ៗ អាចឲ្យយើងសរសេរបានប៉ុន្មានថ្ងៃ ? ប៉ុន្មានខែ ?” ។

បើអធិប្បាយអំពីសត្វវិញ ដូចជាដំរី ក្នុង “យោបល់” សិស្សមិនត្រូវនិយាយថា : “ដំរីមានប្រយោជន៍ណាស់” ។ គេត្រូវនាំសិស្សឲ្យរកសេចក្ដីដូចបែបនេះវិញ “បើដំរីមានតែក្ទកធំ សមល្មមនឹងខ្លួនវា តើវានឹងគាប់យ៉ាងណាទៅ ។ បើជើងវាស្រៀវវិញ តើជើងនោះអាចទ្រខ្លួនវារួចឬទេ ?” ។

ក្នុងសេចក្ដីអធិប្បាយរបស់សិស្ស ឧបមា : អំពីឆ្កែ សិស្សច្រើនដាក់ដូច្នេះ “ខ្ញុំស្រឡាញ់ឆ្កែខ្ញុំណាស់” ។ គួរតែនាំសិស្សឲ្យសរសេរយ៉ាងនេះទៅវិញ “បើឪពុកម្ដាយខ្ញុំគ្មានឆ្កែទេ គាត់ត្រូវរកមនុស្សឲ្យចាំផ្ទះនៅវេលាយប់ ដូច្នេះឆ្កែជាសត្វមានប្រយោជន៍ដល់ម្ចាស់វា គេត្រូវបំប៉នបំណាំវាឲ្យគ្រប់គ្រាន់ ។ តែកាលណាវាឆ្កួត វានឹងឲ្យទោសដល់មនុស្សយើងជាមិនខាន” ។

## របៀបកែតែងសេចក្ដី

តាមធម្មតា សិស្សត្រូវរៀបចំ រួចចម្លងសេចក្ដីអធិប្បាយរបស់វាដាក់ក្នុងសៀវភៅ ឬក្រដាស់មួយសន្លឹក ក្រៅពីពេលរៀន នៅឯផ្ទះរបស់វា ៗ

### ១– ការកែសៀវភៅនីមួយ ៗ ។

លុះអស់រយៈកាល គេត្រូវប្រមូលសៀវភៅ ឬក្រដាសនោះ យកមកអានហើយគូសពីក្រោមនឹងទឹកក្រហម ពាក្យណាដែលសរសេរមិនត្រឹមត្រូវ ឃ្លាណាដែលឆ្គង ដែលគេស្ដាប់មិនបាន ដែលមានប្រើពាក្យមិនសមរម្យ រួចគេត្រាពិន្ទុឲ្យតាមការគួរ ។

**២– ការកែនៅលើក្ដារខៀនបញ្ជរ ។** ដល់ពេលតែងសេចក្ដីបន្ទាប់ គេឲ្យសិស្សចម្លងដាក់លើក្ដារខៀនបញ្ជរ មុនពេលចូល-រៀន ពាក្យណា ឃ្លាណាដែលគេបានគូសពីក្រោមនឹងទឹកក្រហម ៗ ដល់សិស្សទាំងអស់គ្នាចូលមកក្នុងថ្នាក់រៀន គេនាំសិស្សនោះឲ្យកែពាក្យ ឬឃ្លា ដែលសរសេរនៅលើក្ដារខៀនបញ្ជរ ។ ឯសិស្សនីមួយ ៗ វាកែពាក្យ ឬឃ្លាក្នុងសៀវភៅរបស់វា ។

នៅទីបំផុត គេឲ្យសិស្សពីរ - បីនាក់ អានសេចក្ដីដែលវាតែងបានល្អត្រឹមត្រូវ ឲ្យសិស្សទាំងអស់គ្នាស្ដាប់ ។

## របៀបកែការហាត់គ្រប់មុខ

ការឲ្យសិស្សបំពេញឃ្លា ឲ្យសិស្សឆ្លើយនឹងពាក្យចោទ ការកែចំណោទ ។ល។ គេត្រូវកែនៅក្នុងកន្លែងរៀន ។

១– កែនៅលើក្ដារខៀនបញ្ឈរ ។ គេត្រូវចោទសួរចំពោះទៅសិស្សទាំងអស់គ្នា ។ គេឲ្យសិស្សដែលលើកដៃបំពេញឃ្លាឆ្លើយនឹងពាក្យសួរ តែមាត់ទទេ ។ គេត្រូវចាត់សិស្សម្នាក់ឲ្យទៅឈរជិតក្ដារខៀនបញ្ឈរ រកសិស្សណាដែលសរសេររហ័ស ហើយច្បាស់លាស់ផង ដើម្បីឲ្យវាសរសេរនៅលើក្ដារខៀនបញ្ឈរ សេចក្ដីឆ្លើយរបស់គូកនវា គឺចម្លើយណាដែលគ្រូឲ្យសរសេរ ។

២– កែក្នុងសៀវភៅរបស់សិស្ស ។

លុះធ្វើដូចបានពណ៌នាខាងលើនេះរួចហើយ សិស្សទាំងអស់បើកសៀវភៅ ហើយកែការហាត់របស់វាតាមគំរូដែលនៅលើក្ដារខៀនបញ្ឈរ ។

ក្នុងពេលនេះ គ្រូត្រូវដើរត្រួតត្រាមើលសិស្ស ហើយនឹងដាក់ពិន្ទុឲ្យការហាត់របស់សិស្សនីមួយ ៗ តាមការគួរ ។

## របៀបបង្រៀនចម្លង – សរសេរតាមសូត្រ

១– សូត្រពាក្យឲ្យសិស្សស្ដាប់ ឲ្យវាថាតាម ។ គេជ្រើស

យកពាក្យក្នុងបទដែលរៀនអានរួចមកហើយ មកសូត្រឲ្យសិស្សស្ដាប់ ឲ្យវាថាតាម ៗ បទនេះគេចុះលើក្ដារខៀនបញ្ឈរ ដើម្បីឲ្យសិស្សទាំងអស់គ្នាមើល ។

២_ ឲ្យសិស្សសរសេរពាក្យក្នុងក្ដារឆ្នួន ។ មុននឹងសរសេរពាក្យនោះ មានសិស្សខ្លះ ដែលពុំសូវស្ទាត់វារកនៅលើក្ដារខៀនបញ្ឈរ ពាក្យដែលគ្រូទើបនឹងសូត្រ រួចទើបវាសរសេរក្នុងក្ដារឆ្នួនរបស់វា ។ តាមរបៀបនេះសិស្សមើលរួច ទើបវាសរសេរ ។ ហេតុនេះហើយបានជាគេប្រើស័ព្ទ "ចម្លង – សរសេរតាមសូត្រ" ។

៣_ កែពាក្យដែលសិស្សទើបនឹងសរសេរ ។ គេឲ្យសិស្សទាំងអស់គ្នាលើកក្ដារឆ្នួន ។ បើមានសិស្សណាសរសេរពាក្យនោះខុស គេឲ្យវាចេញពកន្លែងវា យកទាំងក្ដារឆ្នួនរបស់វាមកផង ។ គេឲ្យវារកនៅលើក្ដារខៀនបញ្ឈរ ពាក្យដែលវាទើបនឹងសរសេរ ឲ្យវាផ្គូរពាក្យរបស់វា នឹងពាក្យដែលគេសរសេរនៅលើក្ដារខៀនបញ្ឈរ តើពាក្យទាំងពីរនេះខុសពីគ្នាត្រង់ណាខ្លះ រួចគេឲ្យវាកែតាមពាក្យដែលសរសេរនៅលើក្ដារ-ខៀនបញ្ឈរ ។

វិធីធ្វើនេះ គេប្រើតែនៅថ្នាក់ណាដែលសិស្សទើបនឹងរៀនអានរៀនសរសេរ ។

## របៀបបង្រៀនសរសេរតាមសូត្រ – រៀបចំ (Dictée préparée)

គេសរសេរបទដែលត្រូវយកមកបង្រៀន ដាក់លើក្ដារខៀនបញ្ជរ មុនពេលចូលរៀន ។

១– គេឲ្យអានបទនោះ ហើយពន្យល់ពាក្យពិបាក ។ ការត្រង់នេះគេធ្វើដូចកាលគេបង្រៀនអាន ។

២– គេឲ្យអាន – បំបែក – សរសេរ ពាក្យដែលត្រូវរៀន ។ ពាក្យនេះគេជ្រើសក្នុងបទដែលទើបនឹងអាន ។

ក) គេឲ្យសិស្សរកពាក្យឯទៀត ដែលមានអក្ខរាវិរុទ្ធ ស្រដៀងគ្នា នៅខាងដើមពាក្យ ឬនៅខាងចុងពាក្យ ។ ឧបមាដូចជា: កង្កែប, អង្គុយ; បញ្ចើម, ជញ្ជាំង; ប៉ុន្តែ, បន្ថែម ។ល។ ប្រសាសន៍, ប្រយោជន៍ ។

ខ) គេនាំសិស្សឲ្យរកពាក្យឯទៀត ដែលមានសំឡេងដូចពាក្យដែលគេបង្រៀន តែមានន័យខុសគ្នា ឧបមាដូចជា: បាត្រ, បាទ, បាត គេឲ្យក៏សរសេរពាក្យនោះនៅកណ្ដាលក្ដារខៀន ។ គេពន្យល់សិស្សឲ្យឃើញច្បាស់ថា ពាក្យនេះគេសរសេរយ៉ាងនេះ ពាក្យនោះគេសរសេរយ៉ាងនោះ ។ ឯគ្រូត្រូវសរសេរពាក្យទាំងនោះ ដែលសិស្សរកបាន នៅលើក្ដារខៀនបញ្ជរតាម ៗ ពួក ។

៣– គេពន្យល់ពាក្យណាដែលអក្ខរាវិរុទ្ធ តាមវិធានវេយ្យាករណ៍ ។ បើគេចង់ដឹងថាសិស្សយល់ហើយឬនៅចំពោះវិធានទីមួយ ៗ គេយកឧទាហរណ៍មកសូត្រឲ្យសិស្សទាំងអស់គ្នាសរសេរក្នុងក្ដារឆ្នួន ។ បើមានសិស្សភាគច្រើនសរសេរមិនត្រូវ គឺថាពុំទាន់យល់ ។

គេមិនយកបទដែលរៀននេះមកសូត្រឲ្យសិស្សសរសេរតាមក្នុងពេលនោះភ្លាម ៗ ទេ ។ គេទុកឲ្យរំលងមួយថ្ងៃ ឬពីរថ្ងៃ ទើបគេយកបទនោះមកសូត្រឲ្យសិស្សសរសេរតាម ។

ម្យ៉ាងទៀតគេជ្រើសយកបទឯណាផ្សេងពីបទនោះមកសូត្រឲ្យសិស្សសរសេរតាម ។ ក្នុងបទនេះគេប្រើពាក្យដែលមានអក្ខរាវិរុទ្ធ ស្រដៀងនឹងពាក្យដែលបានបង្រៀនរួចមកហើយ ។

ក្នុងវេលាដែលសិស្សទាំងអស់ សរសេរតាមសូត្រក្នុងសៀវភៅ គេត្រូវហៅសិស្សម្នាក់ ឲ្យទៅសរសេរតាមសូត្រនៅលើក្ដារខៀនបញ្ឈរ ដែលគេបាំងនឹងកំផែង ឬលើក្ដារខៀនបញ្ឈរដែលគេបង្អិលទៅក្រោយបាន ។ គេយកបទដែលសរសេរលើក្ដារខៀននេះ ឲ្យសិស្សទាំងអស់គ្នាកែ ។

បើគេហាត់សិស្សណាដែលពូកែជាងគេ ឲ្យទៅសរសេរនៅលើក្ដារ-

ខៀនបញ្ជរ នោះមុខជាគ្មានការស៊ូទឹងឆ្ងើរទេ ។ បើគេប្រើសិស្សដែលខ្សោយជាងគេវិញ ឲ្យទៅសរសេរនៅលើក្ដារខៀនបញ្ជរ នោះប្រហែលជាគេកែមិនអស់ទេ ក្នុងពេលសរសេរតាមសូត្រនោះ ។ ហេតុដូច្នេះ គេត្រូវឲ្យសិស្សមធ្យម ទៅសរសេរនៅលើក្ដារខៀនបញ្ជរ ។

## របៀបបង្រៀនសរសេរតាមសូត្រ-បញ្ជាក់ (Dictée de contrôle)

១_ គេអានបទដែលយកមកសូត្រឲ្យសិស្សសរសេរ រួចគេសួរសិស្ស តើក្នុងបទនេះគេនិយាយអំពីអ្វី ? ។

២_ គេសូត្របួន-ប្រាំម៉ាត់ឲ្យសិស្សស្ដាប់ ឲ្យវាថាតាមឲ្យវាសរសេរ ។ គេឲ្យសិស្សថាតាម មុនវាសរសេរ ព្រោះគេចង់បង្វឹកវាឲ្យស្ដាប់សិន មុននឹងសរសេរ ។ បើសិស្សរបស់គេថ្នក់ហើយ គេក៏មិនបាច់ឲ្យវាថាតាមដែរ ។

៣_ គេនាំសិស្សទាំងអស់គ្នា ឲ្យកែបទដែលសិស្សសរសេរនៅលើក្ដារខៀនបញ្ជរ ។ គេឲ្យសិស្សទាំងអស់គ្នា បិទសៀវភៅរបស់វា ។ គេចាត់ឲ្យសិស្សម្នាក់អានមួយឃ្លា គេសួរទៅសិស្សទាំងអស់ថា នរណាឃើញមានខុស ? ។ គេចាត់សិស្សណាម្នាក់ដែលបានលើកដៃ ឲ្យវាទៅកែពាក្យណាដែលវាឃើញនៅលើក្ដារខៀនបញ្ជរ ។

បើមានពាក្យណា ដែលខុសតាមវិធាននៃវេយ្យាករណ៍ គេសួរសិស្សថា ហេតុដូចម្ដេច បានជាគេសរសេរយ៉ាងនេះ ? ។

៤– ឲ្យសិស្សយកសៀវភៅមកកែ តាមបទដែលនៅលើក្ដារខៀនបញ្ជរ ។ គ្រូត្រូវដើរត្រួតត្រាមើលសិស្ស ដែលគេកែសៀវភៅរបស់គេ ។ បើមានពេល គេត្រៀតដាក់ពិន្ទុ ឲ្យសិស្សខ្លះដែរក្នុងពេលនោះ ។

## របៀបបង្រៀនវេយ្យាករណ៍

១– នាំសិស្សឲ្យពិនិត្យ នាម គុណនាម កិរិយាស័ព្ទ ប្រធាន កម្ម ។ល។ ប្រើក្នុងបទដែលរៀនអាន ដែលសរសេរតាមសូត្រ ឬក្នុងឧទាហរណ៍ដែលគេសរសេរដាក់លើក្ដារខៀនបញ្ជរ ។

២– នាំសិស្សឲ្យរកវិធាន ។ បើសិស្សរកពុំឃើញ គេចោទសួរសិស្ស នាំឲ្យរកទាល់តែបាន ។

៣– ឲ្យសិស្សបម្លងឧទាហរណ៍ និងវិធាន ដាក់ក្នុងសៀវភៅទុកធ្វើជាមេរៀន ។ បើសិស្សទីមួយ ៗ មានសៀវភៅវេយ្យាករណ៍ហើយ គេគ្រាន់តែប្រាប់ឈ្មោះសៀវភៅនោះ ព្រមទាំងចង្អុលលេខទំព័រហើយនិងលេខរៀងរបស់មេរៀន ។

## ៤– គេដាក់ការហាត់ឲ្យសិស្សធ្វើ ។

### របៀបបង្រៀនមេសូត្រ

ក្នុងមួយខែ ៗ គេឲ្យយ៉ាងតិចមេសូត្រមួយ យ៉ាងច្រើនមេសូត្រពីរ ។ សិស្សត្រូវចាំមេសូត្ររបស់វាទាំងអស់ ។ ក្នុងមួយពេល គេមិនឲ្យសូត្រតែមេថ្មីនោះទេ គេឲ្យសូត្រទាំងថ្មីទាំងចាស់ ។ គេឲ្យសូត្រដូចជាគេបង្រៀនអានត្រង់ ១ ដែលសិស្សអានម្នាក់ម្ដង ៗ គឺគេមិនឲ្យសិស្សម្នាក់សូត្រមេមួយទាល់តែចប់ទេ សិស្សម្នាក់ ៗ សូត្របានបន្តិច គេឲ្យសិស្សម្នាក់ទៀតសូត្រត ។

### ក) នៅថ្នាក់ដែលសិស្សពុំទាន់ចេះអាន

១ – គ្រូបញ្ចេញសេចក្ដីមួយឃ្លា ដោយច្បាស់លាស់ ហើយមួយ ៗ ផង ។ បើមានពាក្យណាដែលសិស្សពុំទាន់ស្គាល់ន័យរបស់ពាក្យនោះ គេត្រូវពន្យល់ពាក្យនោះសិន ដូចកាលគេបង្រៀនអាន ។

២– ឲ្យសិស្សថាតាមម្នាក់ម្ដង ៗ មួយពួកម្ដង ៗ ។ គេរើសសិស្សណាដែលពូកែជាងគេ ឲ្យថាតាមម្នាក់ម្ដង ៗ រួចឲ្យសិស្សដែលអន់បន្តិច ថាតាមព្រម ៗ គ្នា មួយពួកម្ដង ៗ ។

នៅទីបំផុត គេឲ្យសិស្សដែលខ្សោយជាងគេ ថាតាមម្នាក់ម្ដង ៗ មួយពួកម្ដង ៗ ។

៣– គ្រូបញ្ចេញសេចក្ដីមួយឃ្លាទៀត តពីឃ្លាមុន ។ គេនាំសិស្សឲ្យថាតាម ដូចបានពណ៌នាក្នុង ១ ទី ២ ខាងលើនេះ ។

៤– ឲ្យសិស្សថាតាមទាំងពីរឃ្លា ម្នាក់ម្ដង ៗ មួយពួកម្ដង ៗ ម្នាក់ម្ដង ៗ ដូចក្នុង ១ ទី ២ ខាងលើនេះ ។

គេថែមមួយឃ្លាម្ដង ៗ ឲ្យសិស្សថាតាម ដូចក្នុង ១ ទី ២ លុះអស់បទដែលត្រូវបង្រៀន ។

## ១) នៅថ្នាក់ដែលសិស្សចេះអាន

គេសរសេរមេសូត្រនៅលើក្ដារខៀនបញ្ឈរ មុនពេលចូលរៀន ។

១– គ្រូអានបទនេះមួយចប់ ឲ្យសិស្សស្ដាប់ ព្រមទាំងពន្យល់ពាក្យណាដែលសិស្សពុំទាន់ស្គាល់ន័យរបស់ពាក្យនោះ ដូចកាលបង្រៀនអាន ។

២– ឲ្យសិស្សអានបទនេះ ម្នាក់ម្ដង ៗ មួយពួកម្ដង ៗ ដូចកាលបង្រៀនអាន ។ ក្នុងវេលាដែលសិស្សកំពុងអាន គេលុបពាក្យមួយម្ដង ៗ ។ មុនដំបូងគេលុបពាក្យ បន្ទាប់បន្សំ ដូចជា ប្រធាន កម្ម ៗ

នៅទីបំផុត គេលុបកិរិយាស័ព្ទ ៗ សិស្សនៅតែអានតៗគ្នា ម្នាក់ម្ដងៗ មួយពួកម្ដង ៗ លុះត្រាតែគេលុបបទនោះអស់រលីង នៅលើក្ដារខៀនបញ្ឈរ ៗ

នៅថ្នាក់ឧត្ដមដ្ឋាន បើគេឱ្យសិស្សសរសេរបទនេះឡើងវិញ លើក្រដាសសំណៅមួយសន្លឹក ក៏ជាការល្អដែរ ៗ គេឱ្យកែបទរបស់សិស្ស ដូចជាគេកែបទសរសេរតាមសូត្រ គឺឱ្យសិស្សមធ្យមម្នាក់ចម្លងបទរបស់វា ដាក់លើក្ដារខៀនបញ្ឈរ ដើម្បីឱ្យសិស្សកែទាំងអស់គ្នា ៗ

## របៀបបង្រៀនសរសេរអក្សរផ្ចង់

នៅថ្នាក់តូច ៗ គេមិនបាច់ឱ្យសិស្សដឹកបន្ទាត់ទ្រេត ៗ ស្រប ៗ គ្នាទេ ហើយគេឱ្យសរសេរតែ ១ ភាគ ២ បន្ទាត់ស្របក្នុងសៀវភៅ ក៏ល្មមហើយ ៗ

១_ គ្រូសរសេរអក្សរ ដែលត្រូវបង្រៀននៅលើក្ដារខៀនបញ្ឈរ ព្រមទាំងបង្ហាញសិស្សឱ្យឃើញច្បាស់ថា : អក្សរនេះគេចាប់ពីត្រង់នេះ អក្សរនោះ គេចាប់ពីត្រង់នោះ ៗ គេបង្ហើរស្លាបប៉ាកកាត្រង់នេះ គេសង្កត់ស្លាបប៉ាកកាត្រង់នោះ ៗ

២_ ហៅសិស្សម្នាក់ឱ្យមកសរសេរអក្សរនៅលើក្ដារខៀន

បញ្ឈរ ឲ្យសិស្សទាំងអស់គ្នាមើល តើមានខុសឆ្គងត្រង់ណាខ្លះ ដើម្បីឲ្យគេកែឲ្យបានត្រឹមត្រូវឡើង ។

៣– ឲ្យសិស្សសរសេរទាំងអស់គ្នា ក្នុងក្ដារខៀន ឬ ក្នុងសៀវភៅតែមួយបន្ទាត់សិន ។ ក្នុងពេលនេះ គ្រូត្រូវដើរគន់មើល បើក្នុងមានសិស្សណា សរសេរអក្សរនោះមិនសម ដើម្បីនឹងសរសេរអក្សរនោះបង្ហាញសិស្ស ទុកជាគំរូនៅក្នុងក្ដារខៀន ឬ ក្នុងសៀវភៅរបស់សិស្ស ។

បើមានសិស្សភាគច្រើន សរសេរអក្សរមិនបានល្អ គ្រូត្រូវបញ្ឈប់សិស្សកុំឲ្យសរសេរតទៅទៀត ហើយត្រូវទៅសរសេរអក្សរនោះ នៅលើក្ដារខៀនបញ្ឈរម្ដងទៀត ថែមទាំងពន្យល់ជាថ្មីឡើង ។

៤_ឲ្យសិស្សសរសេរអក្សរ មួយឬពីរបន្ទាត់តទៅទៀត។ តាមធម្មតា អក្សរបន្ទាត់ទី ២ ឬ ទី ៣ ត្រូវមានភាពល្អជាងអក្សរបន្ទាត់ទី ១ ។ គេត្រូវឲ្យសិស្សសរសេរមួយ ៗ ហើយដោយផ្ចិតផ្ចង់ ៗ

## របៀបប្រើឆ្នូរគំនូរ

ក្នុងវិធីនេះ ដំបូងគេត្រូវបង្រៀនសិស្សឲ្យចេះគូសបន្ទាត់ សណ្ដាកឈរ ទ្រេតទៅខាងឆ្វេង – ខាងស្ដាំ គោង និងដៃទទេ ឥតប្រើបន្ទាត់ ហើយមិនឲ្យបង្ហិលសៀវភៅរបស់វាផង គឺសិស្សត្រូវដាក់សៀវភៅរបស់វា

ត្រង់ណានៅលើតុ សៀវភៅនោះត្រូវនៅដដែល ត្រង់កន្លែងនោះ ។

ដើម្បីនឹងបង្រៀនសិស្សឲ្យគូសបន្ទាត់ គេឲ្យវាចុចពងត្រិត ៗ គ្នា រួចគេឲ្យវាគូសបន្ទាត់នឹងខ្មៅដៃរបស់វា យ៉ាងស្រាលលើពងត្រីនោះ ៗ លុះធ្វើយ៉ាងនេះបានត្រឹមត្រូវហើយ ទើបសិស្សគូសសង្កត់នឹងខ្មៅដៃយកជាស្រេច ៗ បើឲ្យសិស្សគូររបស់អ្វី គេត្រូវដាក់របស់នោះនៅចំពីមុខសិស្សដើម្បីឲ្យវាឃើញទាំងអស់គ្នា ។

១ – **គ្រូគូររបស់នោះនៅលើក្ដារខៀនបញ្ឈរ** ដោយសួរសិស្សដែលអង្គុយចំពីមុខរបស់នោះថា: ឯងមើលទៅឃើញបន្ទាត់បែបណា ? គ្រូត្រូវទៅគូសនៅលើក្ដារខៀនបញ្ឈរ បន្ទាត់ដែលសិស្សឃើញនោះគឺ បន្ទាត់ សណ្ដូក ឈរ ទ្រេត កោង ។

គ្រូត្រូវគូរគំនូរពីរទៀតនៅលើក្ដារខៀនបញ្ឈរ គំនូរមួយធ្វើតាមចម្លើយនៃសិស្សដែលអង្គុយខាងស្ដាំ គំនូរមួយទៀតធ្វើតាមចម្លើយនៃសិស្សដែលអង្គុយខាងឆ្វេង ។

នៅថ្នាក់ខ្ពស់ ៗ ក្នុងគំនូរនីមួយ ៗ ត្រូវឲ្យមានបន្ទាត់ឈរត្រង់មួយពុះរបស់នោះជាពីរចំណែក ត្រង់កន្លែងណាដែលគេឃើញនៅជិតខ្លួនគេ ហើយនឹងបន្ទាត់សណ្ដូកមួយ ធ្វើឲ្យឃើញថា របស់ដែលគេគូរនោះដាក់លើឬក្រោម ខ្សែភ្នែករបស់អ្នកគូរ ។

២– គ្រូលុបគំនូរដែលបានធ្វើនៅលើក្ដារខៀនបញ្ឈរ ។

៣– សិស្សនីមួយ ៗ គូររបស់នោះ តាមភាពដែលវាមើលទៅឃើញ ហើយដាក់ស្រមោលផង ។

៤– គ្រូឲ្យពិន្ទុ ។ គ្រូត្រូវទៅអង្គុយត្រង់កន្លែងដែលសិស្សអង្គុយគូរ ផ្ទៀបគំនូរដែលសិស្សធ្វើ នឹងរបស់ដែលឲ្យគូរ ទើបដាក់ពិន្ទុឲ្យគំនូរនីមួយ ៗ តាមការគួរ ។

## របៀបចោទសួរសិស្សម្នាក់ៗ

ពាក្យចោទនីមួយ ៗ ត្រូវឲ្យច្បាស់លាស់ ឲ្យប្រាកដហើយឲ្យល្មមនឹងចំណេះរបស់សិស្សផង ។ ឯពាក្យចោទដែលសន្មតថាមិនប្រាកដនោះ គឺសិស្សឆ្លើយយ៉ាងនេះក៏បាន យ៉ាងនោះក៏បានដែរ ។ គ្រូត្រូវរៀបចំពាក្យចោទទាំងប៉ុន្មានដោយហ្មត់ចត់ ហើយកត់ទុកក្នុងសៀវភៅតែងបង្រៀន ។

គ្រូត្រូវចោទសួរបំពោះទៅសិស្សទាំងអស់គ្នា ។ គេទុកពេលបន្តិចឲ្យសិស្សគិតសិន ។ សិស្សណាដែលរកចម្លើយឃើញ សិស្សនោះត្រូវលើកដៃស្តាំ ។ បើមានសិស្សភាគច្រើនមិនលើកដៃ នោះប្រហែលជាវាមិនបានស្ដាប់ពាក្យចោទរបស់គ្រូ ឬវាមិនយល់ពាក្យចោទនោះ ។ ដូច្នេះ មុននឹងឲ្យសិស្សឆ្លើយ គេឲ្យសិស្សមួយ ឬពីរនាក់ សូត្រពាក្យសួរ

នោះឡើងវិញសិន ។ បើសិស្សណាឆ្លើយមិនរួច គ្រូមិនត្រូវបង្អាប់បន្តុះ បំអកឡកឡឺយ ស្តីបន្ទោសវាឡើយ ។ គ្រូត្រូវធ្វើជាមិនដឹងមិនយល់ ហើយតម្រូវទៅសិស្សម្នាក់ទៀតដែលវាលើកដៃ ឲ្យឆ្លើយតាមពាក្យសួរ ។ បើគ្មានសិស្សណាអាចនឹងឆ្លើយបាន តាមពាក្យចោទនោះទេ ពាក្យសួរនោះជ្រៅពេកលើសបំណេះសិស្ស ។ បើដូច្នេះមែន គ្រូត្រូវកែពាក្យចោទ ត្រូវសួរបែបផ្សេងទៅវិញ ។

ពាក្យចោទសួរមានពីរយ៉ាង :

ក) ពាក្យសួរលំនាំ ;

ខ) ពាក្យសួរបញ្ឆោក ។

គេប្រើពាក្យសួរលំនាំ ក្នុងពេលដែលគេបង្រៀន ។ លុះដល់គេបង្រៀនរួចហើយ បើគេចង់ដឹងថា សិស្សយល់ហើយឬនៅ គេប្រើពាក្យសួរបញ្ឆោក ។

## អំពីនិយាយឆ្លងឆ្លើយគ្នា (La conversation)

សិស្សច្រើនចេះតែឆ្លើយ មិនសូវចេះសួរ ។ ហេតុនេះ គួរយើងបង្ហាត់សិស្សឲ្យចេះឆ្លើយ ចេះសួរ គឺនិយាយឆ្លងឆ្លើយគ្នា ។

និយាយឆ្លងឆ្លើយគ្នាមានពីរយ៉ាង :

ក) និយាយឆ្លងឆ្លើយគ្នាក្នុងវង្សត្រកូល ឧបមា : អ្នកឈ្មោះអ្វី ? អ្នកអាយុប៉ុន្មាន ? ឪពុកអ្នកឈ្មោះអ្វី ? ម្ដាយអ្នកឈ្មោះអ្វី ? ម្ដាយឪពុកអ្នករកស៊ីធ្វើការអ្វី ? គាត់នៅតំបន់ណា ? គាត់មានកូនប៉ុន្មាននាក់ ? ប្រុសប៉ុន្មាន ? ស្រីប៉ុន្មាន ? អ្នកមានបងប្រុសឬទេ ? បងប្រុសអ្នកធ្វើការអ្វី ? អ្នកមានប្អូនស្រីឬទេ ? ប្អូនស្រីអ្នកធ្វើការអ្វី ? ។ល។

ខ) និយាយឆ្លងឆ្លើយគ្នាក្នុងភាគនៃការសិក្សា ឧបមាដូចជា ក្នុងថ្ងៃនេះ គេបង្រៀនអំពីសំលៀកបំពាក់ គេចោទសួរចំពោះទៅលើរូបសិស្សនីមួយ ៗ ដូចមានតទៅ : អ្នកស្លៀកអ្វី ? អ្នកពាក់អ្វី ? នរណាដេរខោអាវនេះឲ្យអ្នក ? ខោអាវរបស់អ្នកថ្លៃប៉ុន្មាន ? ។ល។

តាមពាក្យសួរខាងលើនេះ សិស្សឆ្លើយមិនដូចគ្នាទេ ។ សូមប្រយ័ត្នកុំប្រឡំហាត់ភាសា នឹងហាត់និយាយឆ្លងឆ្លើយគ្នា ។

បើគេសួរថា : ចៅសមស្លៀកអ្វី ? សិស្សទាំងអស់ឆ្លើយដូចគ្នាថា : "ចៅសមស្លៀកខោខ្លី" ។ គេឲ្យសិស្ស ២ - ៣ - នាក់ថាតាម: "ចៅសមស្លៀកខោខ្លី" ។ បង្រៀនបែបនេះ គេហៅថាហាត់ភាសា ។

បើគេប្រើពាក្យសួរនេះ អ្នកស្លៀកអ្វី ? ចៅសមឆ្លើយថា: "ខ្ញុំស្លៀកខោខ្លី" ។ ចៅសុខឆ្លើយថា: "ខ្ញុំស្លៀកខោជើងវែង" ។ នាងសៅឆ្លើយថា: "ខ្ញុំស្លៀកសំពត់" ។ ធ្វើបែបនេះគេហៅថា: បង្ហាត់

និយាយឆ្លងឆ្លើយគ្នា ។

## របៀបបង្ហាត់និយាយឆ្លងឆ្លើយគ្នា

គ្រូចោទសួរចំពោះទៅសិស្សទាំងអស់គ្នា ។ សិស្សណាដែលឆ្លើយរួចហើយ ត្រូវសួរទៅគូកនវាម្នាក់ ដូចជាគ្រូបានសួរវា ។ សិស្សនេះទៀតឆ្លើយរួចហើយ ត្រូវសួរទៅគូកនវាម្នាក់ផ្សេងទៀត ។

គ្រូសួរមួយឃ្លាទៀតចំពោះទៅសិស្សទាំងអស់គ្នា ។ សិស្សណាដែលបានឆ្លើយរួចហើយ ត្រូវសួរទៅគូកនវា ដូចបានពណ៌នាខាងលើនេះ ។ លុះសិស្សឆ្លើយត្រឹមត្រូវហើយ គេឲ្យសិស្សយកពាក្យចោទទាំងពីរឃ្លាមកសួរគូកនរបស់វា ។

គ្រូថែមពាក្យសួរមួយទៀត ។ លុះសិស្សឆ្លើយបានត្រឹមត្រូវហើយ គេឲ្យសិស្សទីមួយ ៗ យកពាក្យចោទទាំងបីមកសួរគូកនរបស់វា ។

កន្លងមួយពេល ៗ គេបង្ហាត់សិស្សឲ្យចេះប្រើពាក្យចោទ ៤ ឬ ៥ ហើយឲ្យចេះឆ្លើយនឹងពាក្យចោទនេះ ក៏ល្មមហើយ ។

លុះអស់ពាក្យសួរ ដែលគេបានរៀបចំទុកជាមុន គ្រូត្រូវចាំស្ដាប់សិស្សវាសួរទៅគ្នាវា ហើយនឹងចាំស្ដាប់សិស្សវាឆ្លើយមកវិញ ដើម្បីនឹងឲ្យសិស្សកែពាក្យចោទ នឹងចម្លើយរបស់វា ។

# របៀបបង្រៀនប្រែភាសា

ជួនគេត្រូវប្រែភាសាខ្មែរ ទៅជាភាសាបារាំង ។ ជួនគេត្រូវប្រែភាសាបារាំង ទៅជាភាសាខ្មែរ ។ ពាក្យខ្មែរនីមួយ ៗ គេប្រែបាន២ – ៣ យ៉ាង ជាភាសាបារាំង ។ ពាក្យបារាំងនីមួយ ៗ គេប្រែបាន ២ – ៣ យ៉ាង ជាភាសាខ្មែរ ។ ឯការប្រែភាសា ក៏ធ្វើដូចជាការតែងសេចក្ដីដែរ ។ គេនាំសិស្សឲ្យប្រែតែមាត់ទទេសិន ដូចមានរបៀបតទៅនេះ :

១_ ឲ្យប្រែពាក្យ ណាដែលពិបាក ដែលសិស្សមិនអាចនឹងប្រែបានដោយខ្លួនឯង ។

២– ឲ្យប្រែឃ្លាទាំងមូល ។ ជួនណាគេស្ដាប់ពុំបាន សេចក្ដីខ្មែរដែលប្រែតាមសេចក្ដីបារាំង ឬ សេចក្ដីបារាំងដែលប្រែតាមសេចក្ដីខ្មែរ ។ ហេតុដូច្នេះ គេឲ្យសម្រួលឃ្លានីមួយ ៗ ឲ្យគេស្ដាប់បាន តាមភាសាដែលគេប្រែមកនោះ ។

៣_ ឲ្យប្រែបទទាំងមូល ។ ការនេះសិស្សត្រូវធ្វើក្រៅពីពេលបង្រៀន ។ លុះអស់រយៈកាលហើយ គេប្រមូលសៀវភៅរបស់សិស្ស យកមកពិនិត្យមើល ដើម្បីនឹងគូសពីក្រោម នឹងទឹកក្រហម ពាក្យណា ឬឃ្លាណា ដែលប្រែមិនសមរម្យ ហើយនឹងដាក់ពិន្ទុឲ្យតាមការគួរ ៗ

គេឲ្យកែការប្រែភាសា ដូចជាគេកែការតែងសេចក្ដី ( សូមមើលរបៀបនេះនៅទំព័រ ១២ ) ។

## របៀបបង្ហាត់សូត្រពាក្យ (Exercices phonétiques)

ក្នុងភាសាខ្មែរមានពាក្យខ្លះ ដែលសិស្សសូត្រមិនត្រឹមត្រូវ ដូចជាក្នុងភាសាបារាំងដែរ ។ ឧបមាដូចជា :

ក) ពាក្យ " រៀប " នឹង " រាប " សិស្សច្រើនថា ដូចបែបនេះ : "ខ្ញុំរាបដំណើរទៅសៀមរៀប" ជំនួស "ខ្ញុំរៀបដំណើរទៅសៀមរាប" ។

ខ) ពាក្យ "រាង" នឹង "រៀង" សិស្សច្រើនថាដូច្នេះ : "យើងត្រូវចៀសរៀងអំពើអាក្រក់" ជំនួស "យើងត្រូវចៀសរាងអំពើអាក្រក់" ។

គេជ្រើសពាក្យបែបនេះ ក្នុងបទដែលបង្រៀនមើលយកមកបង្ហាត់សិស្សឲ្យសូត្រ ព្រមទាំងពាក្យឯទៀតដែលមានសម្លេងស្រដៀងគ្នា ។

គេបង្ហាត់សិស្សឲ្យសូត្រ ពាក្យតែឯកឯង ពាក្យមួយពួក ពាក្យដែលនៅក្នុងមួយឃ្លា តាមរបៀបខាងក្រោមនេះ :

១— **គ្រូសូត្រពាក្យ** ពាក្យមួយពួក ឬពាក្យមួយឃ្លា ឲ្យសិស្សស្ដាប់ ឲ្យរាយឃើញ តើគេធ្វើបបូរមាត់ដូចម្ដេច គេដាក់អណ្ដាតយ៉ាងណា គេរកមធ្យោបាយអ្វីមកធ្វើឲ្យសិស្សឃើញ ដូចជារូបគំនូរ ដូចជាហ្លួច ។ល។

២– ឲ្យសិស្សហៅតាម ម្នាក់ម្ដង ៗ លុះត្រាសិស្សសូត្របានត្រឹមត្រូវ ។ គេមិនឲ្យសិស្សថាតាមមួយពួកម្ដង ៗ ព្រមគ្នាទេ ព្រោះគេមិនអាចនឹងដឹងថា សិស្សនេះសូត្រត្រូវ សិស្សនោះសូត្រខុស ។

## របៀបបង្ហាត់គិតលេខនឹងប្រាជ្ញា (Exercices de calcul mental)

គេបង្ហាត់សិស្សឲ្យគិតលេខនឹងប្រាជ្ញា រវាងប្រហែល ៥ នាទី ខាងដើមវេលាដែលគេបង្រៀននព្វន្ត រង្វាស់រង្វាល់ ឬរេខាគណិតសាស្ត្រ ។

នៅថ្នាក់តូច ៗ គេឲ្យសិស្សថែមចំនួន ២ – ៣ – ៤ – ៥ ទៅលើចំនួនណាមួយ គេឲ្យសិស្សដកចំនួន ២ – ៣ – ៤ – ៥ ពីចំនួនណាមួយ គេឲ្យសិស្សទ្វេចំនួនតូច ៗ គេឲ្យសិស្សរកពាក់កណ្ដាលចំនួននីមួយ ៗ ។

ឧបមាដូចជា បង្ហាត់សិស្ស ឲ្យថែមចំនួន ២ ទៅលើចំនួនណាមួយ គ្រូត្រូវប្រកាសប្រាប់សិស្សទាំងអស់គ្នាថា: យើងត្រូវថែមពីរ ៗ ចាប់ពី១ ទៅ ។ សិស្សទាំងអស់ប្រុងខ្លួនចាំឆ្លើយ ។ គ្រូចាត់សិស្សនេះឲ្យឆ្លើយតែមាត់ទទេថា (៣) ចាត់សិស្សម្នាក់ទៀតឲ្យឆ្លើយត ។ សិស្សនោះត្រូវឆ្លើយថា (៥) ។ គេឲ្យសិស្សថែមពីរ ៗ យ៉ាងនេះតែមាត់ទទេ ទៅដល់ចំនួនណាដែលគេបានបង្រៀនរួចមកហើយ គឺដូចជាគេបានបង្រៀនដល់ចំនួន (៣០) គេមិនឲ្យហួសពីចំនួននេះទេ ។

ឧបមាដូចជា បង្ហាត់សិស្សឲ្យដកពីរ ៗ ពីចំនួនណាមួយ គ្រូត្រូវប្រកាសប្រាប់សិស្សទាំងអស់គ្នាថា : យើងត្រូវដកពីរ ៗ ពី ២៩ ទៅ ។ សិស្សទាំងអស់ប្រុងខ្លួនចាំឆ្លើយ ។ សិស្សនេះត្រូវឆ្លើយថា ( ២៧ ) សិស្សនោះត្រូវឆ្លើយតទៅទៀតថា ( ២៥ ) ។ គេឲ្យសិស្សដកពីរ ៗ តែមាត់ទទេ លុះត្រាតាល់តែអស់ចំនួន ។

ដើម្បីនឹងថែម ៣ – ៤ – ៥ ទៅលើចំនួនណាមួយ ឬនឹងដក ៣ – ៤ – ៥ ពីចំនួនណាមួយ គេធ្វើដូចរបៀបខាងលើនេះដែរ ។

## របៀបបង្រៀនគិតលេខនឹងប្រាជ្ញា (calcul mental)

គេបង្រៀនឲ្យគិតរកនឹងប្រាជ្ញា ដើម្បីឲ្យចេះថែមចំនួនមួយ ទៅលើចំនួនមួយ ឲ្យចេះដកចំនួនមួយពីចំនួនមួយ ឲ្យចេះរកចំនួនដែលឡើងច្រើនដង ឲ្យចេះរកចំនួនដែលថយចុះច្រើនដង ។

ឧបមាដូចជា : ៥៧ + ៣២ ។

គេគិតដូច្នេះ ៥៧ នឹង ៣០ ត្រូវជា ៨៧

៨៧ នឹង ២ " ៨៩

គេគិតយ៉ាងនេះ ព្រោះលេខនៅក្នុងខ្ទង់រាយ (៣២) តូច ។

ឧបមាដូចជា: ៤៦ + ២៧ ។

គេគិតដូច្នេះ ៤៦ នឹង ៣០ ត្រូវជា ៧៦

៧៦ ដក ៣ នៅសល់ ៧៣ ។

គេគិតយ៉ាងនេះ ព្រោះលេខក្នុងខ្ទង់កាយ (២៧) ធំ ។

១– គ្រូនាំសិស្សឲ្យគិតរកនឹងប្រាជ្ញា ម្នាក់មួយៗ មួយពួកមួយៗ ដូចក្នុងឧទាហរណ៍ខាងលើនេះ លុះត្រាសិស្សយល់ទាំងអស់គ្នា រួចគេឲ្យវារកវិធាន ។

២– ការហាត់ក្នុងក្តារឆ្នួន ។ គេតាំងលេខនៅលើក្តារខៀនបញ្ឈរ គេទុកឲ្យសិស្សគិតរក ដូចក្នុងឧទាហរណ៍ខាងលើនេះ រួចគេឲ្យសិស្សទាំងអស់គ្នា សរសេរចម្លើយរបស់វាដាក់ក្នុងក្តារឆ្នួន ហើយឲ្យលើកក្តារឆ្នួននោះបង្ហាញ ។ បើមានសិស្សណាឆ្លើយខុស គេឲ្យវាគិតរកដូចក្នុងខទី ១ ។

សូមកុំច្រឡំគិតរកនឹងប្រាជ្ញា នឹងការហាត់ធ្វើលេខតែមាត់ទទេ ។ ដូចជា ៤៦ + ២៧ សិស្សធ្វើលេខនេះតែមាត់ទទេដូច្នេះ: ៦ នឹង ៧ ត្រូវជា ១៣ ។ ១ នឹង ៤ ត្រូវជា ៥ ។ ៥ នឹង ២ ត្រូវជា ៧ ។ រួមទាំងអស់ត្រូវជា ៧៣ ។ ឯការគិតរកនឹងប្រាជ្ញាគេធ្វើតាមក្បួន ។

## របៀបបង្រៀនផ្សំចំនួន សរសេរនិងអានលេខ

ដើម្បីនឹងបង្រៀនផ្សំចំនួន ឲ្យឃើញជាក់ស្ដែង គេត្រូវយកគ្រាប់ឈើ ផ្លែឈើ ឬចង្កឹះមកប្រើ ៗ បើចំនួននោះតិចទេ គេប្រើម្រាមដៃនិងម្រាមជើង ៗ

១_ គ្រូបង្ហាញចំនួនឲ្យសិស្សឃើញ ៗ

ក) ចំនួនពី ១ ដល់ ៥

គេយកគ្រាប់ឈើ ឬចង្កឹះ ឬម្រាមដៃ ចំនួន ៣–២–៤–១–៥ មកបង្ហាញឲ្យសិស្សឃើញ ៗ

២– គ្រូត្រាសៅលើក្ដារខៀនបញ្ឈរលេខ ៣–២–៤–១–៥ ដោយច្បាស់លាស់ឲ្យសិស្សមើល ៗ គេបង្រៀនសិស្សឲ្យចេះសរសេរលេខអស់នោះ ដូចជាគេបង្រៀនសិស្សឲ្យសរសេរអក្សរ (សូមមើលរបៀបបង្រៀនសរសេរអក្សរនៅទំព័រទី ៤) ៗ

បើត្រូវបង្រៀនចំនួន ៧ គ្រូត្រូវធ្វើឲ្យសិស្សឃើញជាក់ច្បាស់ថា ហេតុអ្វីបានជាគេឲ្យឈ្មោះចំនួននោះប្រាំពីរ ៗ គេយកគ្រាប់ឈើ ឬចង្កឹះ ឬម្រាមដៃ ៥ ហើយនិង ២ មកផ្សំគ្នាឲ្យសិស្សឃើញ : ៥ ហើយនិង ២ ត្រូវជា ៧ ៗ

គេផ្សំចំនួន ៩ – ៦ – ៨ ឲ្យសិស្សឃើញ ដូចជាចំនួន ៧ ដែរ ។

៩ គេយក ៥ ផ្សំនឹង ៤ ទើបបានជា ៩ ។

៦ –ដ– ៥ –ដ– ១ –ដ– ៦ ។

៨ –ដ– ៥ –ដ– ៣ –ដ– ៨ ។

### ១) ចំនួនពី ១០ ដល់ ១៥

គេយកគ្រាប់ឈើ ឬចង្កឹះ មកផ្សំឲ្យសិស្សមើល ។

•បមាដូចជា ចំនួន ១៣ គេយកចង្កឹះ ១០ ហើយនឹងចង្កឹះ ៣ មកផ្សំគ្នា ។ គេប្រាប់សិស្សថា ១០ ហើយនឹង ៣ ត្រូវជា ១៣ ។ គេគ្រាលេខ ១៣ នៅលើក្ដារខៀនបញ្ឈរឲ្យសិស្សមើល ។ គេបង្ហាញឲ្យសិស្សឃើញថា : ខ្ទង់រាយនៅខាងស្ដាំ ខ្ទង់ដប់នៅខាងឆ្វេង ។

ដើម្បីនឹងបង្រៀនចំនួនឯទៀត ដូចជា ១៥ – ១២ – ១៦ ។ល។ គេប្រើរបៀបដូចខាងលើនេះដែរ ។

គេមិនផ្សំចំនួនទាំងអស់បង្ហាញសិស្សទេ គេឲ្យសិស្សផ្សំចំនួនខ្លះផងនឹងគ្រាប់ឈើ ឬនឹងចង្កឹះ ឲ្យរកសរសេរលេខនោះ (ដូចជា ១៤.១៧-១១ –១៩ – ១២ គឺចំនួនដែលគេមិនទាន់បង្ហាញ) នៅលើក្ដារខៀនបញ្ឈរ ។

ដើម្បីនឹងផ្សំចំនួន ពី ២០ ដល់ ២៩ ពី ៣០ ដល់ ៣៩

ពី ៤០ ដល់ ៤៩ ។ល។ គេធ្វើដូចរបៀបខាងលើនេះផង ។ បើចំនួននោះច្រើនពេក គេរកបន្ទះមកបង្ហាញសិស្សមិនគ្រប់ គេយកបន្ទះមួយដែលគេសន្មតឲ្យដឹងថា បន្ទះនេះជំនួស ១០ បន្ទះនោះជំនួស ១០០ ។

៣– **ឲ្យសិស្សសរសេរចំនួនក្នុងក្ដារខៀន** រួចគេឲ្យវាលើកក្ដារខៀនបង្ហាញ ។ បើមានសិស្សណាសរសេរលេខនោះខុស គេឲ្យវាកែតាមលេខដែលគេបានសរសេរនៅលើក្ដារខៀនបញ្ឈរ ។ បើសិស្សចេះគាន–ចេះសរសេរ គេឲ្យវាសរសេរចំនួននោះជាអក្សរ ។

៤– **ឲ្យសិស្សអានលេខ** ដែលគេបានបង្រៀនហើយ ហើយដែលគេបានសរសេរទុកនៅលើក្ដារខៀនបញ្ឈរ រួចគេលុបលេខអស់នោះចេញ ។

៥– **គ្រូត្រូវឲ្យសិស្សសរសេរនៅក្នុងក្ដារខៀន** លេខដែលគេបានបង្រៀនរួចមកហើយ ។

នៅទីបំផុត គេឲ្យសិស្សរៀនរាប់ លេខទាំងអស់ដែលគេបានបង្រៀន ។

## របៀបបង្រៀនធ្វើលេខ

គេទាញឧទាហរណ៍ដោយដាក់ស្ដង់យកមកបង្ហាញសិស្សឲ្យឃើញ

ច្បាស់ថា  បែបនេះគេត្រូវធ្វើលេខបូក  បែបនោះគេត្រូវធ្វើលេខសង បែបយ៉ាងនេះគេធ្វើលេខគុណ  បែបយ៉ាងនោះគេត្រូវធ្វើលេខចែក ។

ដើម្បីនឹងធ្វើឲ្យសិស្សឃើញថា គេត្រូវប្រើលេខគុណ គួរគេយកឧទាហរណ៍យ៉ាងនេះ សៀវភៅមួយថ្លៃ ១២រ, សៀវភៅ ៦ ថ្លៃកើនឡើងច្រើនដងទៅទៀត គឺឡើងប្រាំមួយដង ។

ដើម្បីនឹងធ្វើឲ្យសិស្សឃើញថា ហេតុដូចម្ដេចគេប្រើលេខចែក គួរគេយកឧទាហរណ៍ដូចនេះ: ជាងម្នាក់ធ្វើការមួយអាទិត្យបាន ១៨២រ, ។ បើធ្វើបានតែមួយថ្ងៃទេ ជាងនោះត្រូវបានប្រាក់ថយចុះមកជាច្រើនដង គឺចុះប្រាំពីរដង ។

គេតាំងលេខនៅលើក្ដារខៀនបញ្ឈរ ព្រមទាំងពន្យល់សិស្ស អំពីរបៀបដែលគេតាំងលេខនោះ ។

**១– គ្រូធ្វើលេខនៅលើក្ដារខៀនបញ្ឈរ** ដោយចោទសួរសិស្សទាំងអស់គ្នា ។ គ្រូគ្រាន់តែចាំសរសេរចម្លើយរបស់សិស្ស នៅលើក្ដារខៀនបញ្ឈរ ។

**២– ឲ្យសិស្សម្នាក់មកធ្វើលេខនៅលើក្ដារខៀនបញ្ឈរ ។**

គេមិនយកលេខដែលធ្វើអម្បាញ់មិញមកឲ្យសិស្សធ្វើទេ ។ គេយកលេខមួយទៀតស្រដៀងគ្នាមកឲ្យសិស្សធ្វើ ដើម្បីចង់ដឹងថាយល់ហើយឬនៅ។

បើសិស្សនេះធ្វើលេខទៅដោយមានខុសឆ្គង ឬធ្វើទៅមិនរួច គ្រូត្រូវសួរទៅសិស្សណា ដែលបានលើកដៃ ៗ ឯសិស្សដែលធ្វើលេខនៅលើក្តារខៀនបញ្ឈរ ត្រូវថាតាមគេ ហើយត្រូវធ្វើលេខនោះតទៅទៀត ៗ

៣– ឲ្យសិស្សទាំងអស់គ្នាធ្វើលេខក្នុងក្តារឆ្នួន ៗ គេសូត្រលេខឲ្យសិស្សសរសេរក្នុងក្តារឆ្នួន រួចគេទុកឲ្យបានធ្វើលេខនោះ ៗ លុះអស់រយៈកាល គេឲ្យបានលើកក្តារឆ្នួនបង្ហាញ ៗ សិស្សណាដែលធ្វើលេខខុសក្នុងក្តារឆ្នួន ត្រូវទៅធ្វើលេខនោះ នៅលើក្តារខៀនបញ្ឈរ ៗ បើបានធ្វើទៅមិនរួច ឬដោយមានខុសឆ្គង គេឲ្យសិស្សដែលលើកដៃជួយ ៗ

៤– នៅថ្នាក់ខ្ពស់ ៗ គេនាំសិស្សឲ្យរកមូលវិធាន ៗ

## របៀបកែការហាត់ធ្វើលេខ

គេកែការហាត់ធ្វើលេខ ដូចជាគេកែការហាត់គ្រប់មុខ ដែលបានពណ៌នារួចមកហើយក្នុងទំព័រទី ១៣ ៗ

១– កែនៅលើក្តារខៀនបញ្ឈរ ៗ គេចាត់សិស្សម្នាក់ គឺសិស្សណាដែលសរសេររហ័សហើយច្បាស់លាស់ផង ឲ្យទៅឈរជិតក្តារខៀនបញ្ឈរ ដើម្បីចាំសរសេរចម្លើយរបស់គូកនវា ៗ គេចោទសួរចំពោះទៅសិស្សទាំងអស់គ្នា ៗ គេចាត់សិស្សម្នាក់ឲ្យធ្វើលេខ តែមាត់ទទេពី

កន្លែងវា ។ គេឲ្យសិស្សដែលឈរជិតក្ដារខៀនបញ្ឈរសរសេរចម្លើយរបស់សិស្សនោះ ។ ក្នុងលេខនីមួយ ។ គេឲ្យសិស្ស ២-៣ នាក់ធ្វើ ។ ម្នាក់ធ្វើបានបន្តិច គេហៅសិស្សម្នាក់ទៀតឲ្យធ្វើតទៅ ។ បើមានសិស្សណាឆ្លើយខុស សិស្សឯទៀតត្រូវលើកដៃ ។

២- កែក្នុងសៀវភៅរបស់សិស្ស ។ គេឲ្យសិស្សទាំងអស់គ្នា កែការហាត់របស់វា តាមលេខដែលគេបានធ្វើនៅលើក្ដារខៀនបញ្ឈរ ។

## របៀបបង្រៀនដោះស្រាយចំណោទ

១- ឲ្យសិស្សអានចំណោទ ដែលគេសរសេរដាក់លើក្ដារខៀនបញ្ឈរ មុនពេលចូលរៀន ។ គេពន្យល់ពាក្យណាដែលសិស្សពុំទាន់ស្គាល់ ។

២- គ្រូចោទសួរសិស្សក្នុងចំណោទនោះ ដូចមានតទៅ : ចំនួននេះ គឺអ្វី ? ចំនួននោះ គឺអ្វី ? ក្នុងចំណោទនេះ គេឲ្យយើងដឹងអ្វីខ្លះ ឬគេប្រាប់អ្វីខ្លះ ? ។

ក្នុងចំណោទនេះ គេឲ្យយើងរកអ្វី ឬគេសួរអ្វី ? ។ ឧបមា គេសួរថ្លៃដើម ។ គ្រូសួរទៅសិស្សទាំងអស់ថា : គេធ្វើយ៉ាងដូចម្ដេចទើបឃើញថ្លៃដើម ? សិស្សត្រូវឆ្លើយថា : គេយកថ្លៃលក់មកកាត់ចំណេញចេញ ។

គ្រូសួរទៅសិស្សតទៅទៀតថា : យើងស្គាល់ហើយឬនៅថ្លៃលក់? គេប្រាប់ចំណេញហើយឬនៅ? ។

គេសួរដេញតៗ ដូចរបៀបខាងលើនេះ រហូតទៅដល់ចម្លើយនៃចំណោទនោះ ។

## របៀបដោះចំណោទ

គេដោះចំណោទ ដូចជាគេដោះការហាត់ធ្វើលេខ ដែលបានពណ៌នាខាងលើនេះ ឬដូចជាគេដោះការហាត់គ្រប់មុខ ដែលបានរៀបរាប់រួចមកហើយ ក្នុងទំព័រលេខ ១៣ ។

## របៀបបង្រៀនរង្វាស់

នៅថ្នាក់តូចៗ គេបង្រៀនសិស្សឲ្យស្គាល់ ឲ្យចេះប្រើរង្វាស់ដែលគេប្រើជាធម្មតា ។

ដើម្បីនឹងបង្រៀនរង្វាស់ទីមួយៗ ដូចជា ម៉ែត្រ ដេស៊ីម៉ែត្រ ហត្ថ ចំអាម ។ល។ គេធ្វើដូចមានរបៀបតទៅនេះ :

**១– ឲ្យពិនិត្យរង្វាស់ៗ** គេមិនគ្រាន់តែធ្វើឲ្យសិស្សស្គាល់រូបរាងរង្វាស់ទីមួយៗនោះទេ ។ គេធ្វើយ៉ាងម្ដេចឲ្យសិស្សឃើញថា រង្វាស់

នេះប្រវែងប៉ុណ្ណេះ រង្វាស់នោះប្រវែងប៉ុណ្ណោះ ៗ ឧបមាដូចជាបង្រៀនអំពីហត្ថ គេយកឈើ ឬ បន្ទះឫស្សី ឬ ផ្ដៅមួយកំណាត់ មកបង្ហាញសិស្សក៏បានដែរ ឲ្យតែវត្ថុនោះមានប្រវែង ១ ហត្ថ ៗ គេឲ្យសិស្សបង្ហាញប្រវែង១ហត្ថនៅលើតួរបស់វា ទីងចង្អុលដៃវាទាំងពីរ គេយកហត្ថទៅវាស់ប្រវែងដែលសិស្សបង្ហាញនោះ ៗ គេឲ្យសិស្សរកក្នុងកន្លែងរៀន របស់អ្វីដែលមានប្រវែង ១ ហត្ថ ហើយគេឲ្យវាយកហត្ថទៅវាស់របស់នោះ ៗ

២– ឲ្យស្មាន ឲ្យវាស់ ៗ គេរកក្នុងកន្លែងរៀន របស់អ្វីដែលមានប្រវែងធំជាងហត្ថ ២-៤-៣-៥ ដង ឲ្យសិស្សទាំងអស់គ្នាមើល ស្មាន រួចឲ្យវាសរសេរចម្លើយរបស់វាដាក់ក្នុងក្ដារខៀន ៗ សិស្សណាឆ្លើយខុស ត្រូវយកហត្ថទៅវាស់របស់នោះ ៗ

៣– ឲ្យសង្កេតសណ្ឋាននៃរង្វាស់នីមួយ ៗ ហើយនឹងរកប្រយោជន៍នៃរង្វាស់នោះ ៗ

បើរង្វាស់ ដែលគេបង្រៀននោះធំជាង ហត្ថ ជាងម៉ែត្រ ដូចជា សិន ដេកាម៉ែត្រ ហិកតូម៉ែត្រ ។ល។ គេនាំសិស្សចេញពីកន្លែងរៀន គេឲ្យវាវាស់ពីត្រង់នេះ ទៅត្រង់នោះ ដើម្បីឲ្យវាឃើញប្រាកដជា ប្រវែងនេះគេហៅថា ១ សិន ប្រវែងនោះគេហៅថា ១ ហិកតូម៉ែត្រ ៗ

# របៀបបង្រៀនរង្វាល់

១– ឲ្យពិនិត្យរង្វាល់ ។ ដើម្បីនឹងបង្រៀនរង្វាល់តូច ៗ ដូចជា លីត្រ ដេស៊ីលីត្រ ។ល។ គេមិនគ្រាន់តែយករង្វាល់នោះ មកបង្ហាញសិស្សទេ គេត្រូវធ្វើម្ដេចឲ្យសិស្សឃើញច្បាស់ ចំណុះរបស់រង្វាល់នោះ ។

ឧបមាដូចជា បង្រៀនអំពីដេស៊ីលីត្រ គេចាក់ទឹកទៅក្នុងដេស៊ីលីត្រ រួចគេផ្ទេរទឹកនោះទៅក្នុងកែវ ១ ហើយគេបង្ហាញសិស្សថា: នេះទឹក ១ ដេស៊ីលីត្រ ។ គេឲ្យសិស្សរករបស់អ្វីដែលគេប្រើជាធម្មតា ហើយដែលមានចំណុះ ១ ដេស៊ីលីត្រ ។

២– ឲ្យស្មាន ឲ្យវាល់ ។ គេយកកែវ ១ ផ្សេងទៀត មកចាក់ទឹកឲ្យច្រើនជាង ១ ដេស៊ីលីត្រ ២–៤–៣–៥ ដង ដាក់ជិតកែវដែលមានទឹក ១ ដេស៊ីលីត្រ ហើយឲ្យសិស្សទាំងអស់គ្នាមើល ស្មាន រួចឲ្យវាសរសេរចម្លើយរបស់វាដាក់ក្នុងក្ដារឆ្នួន ។ សិស្សណាឆ្លើយខុស គេឲ្យសិស្សនោះទៅវាល់ ។

៣– ឲ្យសង្កេតសណ្ឋាននៃរង្វាល់នីមួយ ៗ ហើយនឹងរកប្រយោជន៍នៃរង្វាល់នោះ ។

បើគេបង្រៀនរង្វាល់ធំ ៗ ដូចជា: ដេកាលីត្រ ហិកតូលីត្រ

កន្តាំង តៅ ។ល។ គេនាំសិស្សឲ្យពិនិត្យបែបយ៉ាងនេះ ។ គេដាក់ដីខ្សាច់ ឬអាចម៍រណារ ឬអង្កាមទៅក្នុងដេកាលីត្រ ឬកន្តាំង រួចគេដាក់ដីខ្សាច់នោះ ឬអាចម៍រណារនោះ ឬអង្កាមនោះ គរនៅលើដី ដើម្បីឲ្យសិស្សឃើញច្បាស់ថា : នេះចំណុះ ១ ដេកាលីត្រ នេះចំណុះ ១ កន្តាំង ។

គេឲ្យសិស្សរករបស់អ្វីដែលគេប្រើជាធម្មតា ហើយដែលមានចំណុះប្រហែល ១ ដេកាលីត្រ ឬ ១ កន្តាំង ។

បើគេចង់ឲ្យសិស្សស្មាន គេដាក់ដីខ្សាច់ ឬ អាចម៍រណារ ឬ អង្កាម ១ គំនរទៀត ជិតគំនរដែលគេបង្ហាញ រួចគេឲ្យវាស្មាន ឲ្យរាល់ ។

## របៀបបង្រៀនទម្ងន់

១– ឲ្យពិនិត្យទម្ងន់ ។ គេមិនគ្រាន់តែឲ្យសិស្សស្គាល់រូបរាងកូនទម្ងន់នីមួយ ៗ ទេ ។ គេឲ្យសិស្សបំណាំទម្ងន់នីមួយ ៗ ដូចជា នាឡិ ដេកាក្រាម ហិកតូក្រាម ។ល។ ដោយលើកស្ទង់នឹងដៃ ។

២– ឲ្យស្មាន ឲ្យថ្លឹង ។ ដើម្បីឲ្យសិស្សស្មានវត្ថុនីមួយៗ គេឲ្យសិស្សកាន់នៅដៃម្ខាង ទម្ងន់ដែលគេបង្រៀន នៅដៃម្ខាងទៀត វត្ថុដែលគេឲ្យស្មាន ។ សិស្សណាស្មានខុស គេឲ្យសិស្សនោះយកវត្ថុទៅថ្លឹងនឹងជញ្ជីង ។

៣_ ឲ្យសង្កេតសណ្ឋាននៃកូនទម្ងន់ ហើយនឹងជញ្ជីង ដែលគេប្រើជាធម្មតា ។

## របៀបបង្រៀនរូបិយវត្ថុ

១– ឲ្យពិនិត្យរូបិយវត្ថុ ។ សិស្សសំគាល់ដោយពណ៌ ក្បាច់ រចនា សូរសម្លេង លេខ ឬ អក្សរ ។

២– ឲ្យរៀនប្តូរ នឹងថែមប្រាក់ ។ ដើម្បីនឹងហ្វឹកហ្វឺនសិស្ស ឲ្យចេះប្តូរ ឬថែមប្រាក់ ត្រូវឲ្យមានរូបិយវត្ថុជាច្រើន ។ បើមានរូបិយវត្ថុ មិនគ្រប់គ្រាន់ទេ គួរយកក្រដាសក្រាស់ដែលមានពណ៌ផ្សេងៗពីគ្នា មក កាត់ជារង្វង់មូល ជាកង ៤ ជ្រុងទ្រវែង មានតូច មានធំ ដំនួសរូបិយវត្ថុ ដែលគេចាយរាយសព្វថ្ងៃ ។

ដើម្បីនឹងប្តូរប្រាក់ គេឲ្យសិស្សម្នាក់យកប្រាក់របស់វាទៅដូរនឹងប្រាក់ របស់សិស្សម្នាក់ទៀត ដូចគេតែងធ្វើជាធម្មតា ។ ដើម្បីនឹងបង្ហាត់សិស្ស ឲ្យចេះថែមប្រាក់ គេឲ្យសិស្សម្នាក់ធ្វើជាអ្នកលក់ សិស្សម្នាក់ទៀតធ្វើជា អ្នកទិញ ។ សិស្សដែលធ្វើជាអ្នកលក់ ត្រូវចេះថែមប្រាក់ទៅឲ្យគេ ដូចជាអ្នកលក់ទំនិញ ។ សិស្សដែលទទួលប្រាក់ពីគេ ត្រូវឲ្យចេះរាប់ប្រាក់ នោះ ដោយត្រឹមត្រូវ ។

នៅថ្នាក់ខ្ពស់ ៗ គេឲ្យសិស្សពិនិត្យរង្វាស់ ឬ រង្វាល់ ជាប្រធានរួច ហើយ គេឲ្យរករង្វាស់ ឬ រង្វាល់ ដែលធំ ឬ តូចជាងរង្វាស់ ឬ រង្វាល់ជាប្រធាននោះ ៗ គេឲ្យសិស្សដឹងច្បាស់ថា រង្វាស់ ឬ រង្វាល់នីមួយ ៗ ធំ ឬ តូចជាងគ្នាប៉ុន្មានដង ៗ គេហ្វឹកហ្វឺនសិស្ស ឲ្យចេះសរសេរ ចេះអានចំនួននៃរង្វាស់ ឬ រង្វាល់នីមួយ ៗ ៗ

## របៀបបង្រៀនរេខាគណិតសាស្ត្រ (La géométrie)

. ដើម្បីនឹងបង្រៀន ឧបមាដូចជាផ្ទៃរាងបួនជ្រុងទ្រវែង គេគូរផ្ទៃនោះនៅលើក្ដារខៀនបញ្ឈរ ៗ

១– នាំសិស្សពិនិត្យ ជ្រុង មុំ បណ្ដោយ ទទឹង បាត កំពស់ ៗ គេឲ្យសិស្សរក នៅក្នុងថ្នាក់រៀន របស់អ្វីដែលមានរាងដូចផ្ទៃដែលទើបនឹងពិនិត្យនេះ ៗ គេឲ្យសិស្សរកអត្ថន័យ ៗ

២– ធ្វើយ៉ាងម្ដេចឲ្យសិស្សឃើញច្បាស់ អំពីដំណើរដែលគេ :

ក– រកបរិវេណ ៗ ឧបមា ដូចជាទីធ្លាមួយរាងបួនជ្រុងទ្រវែង បណ្ដោយមាន ៥ ម. ទទឹង ៣ ម. ៗ គេយកបណ្ដោយ ៥ ម. ថែមទទឹង ៣ ម. ថែមបណ្ដោយ ៥ ម. ទៀត ទទឹង ៣ ម. ទៀត ឬយក

បណ្ដោយ ៥ ម. ថែមទទឹង ៣ ម. មកទៀត គឺ ប + ទ + ប + ទ. ឬ (ប × ២) + (ទ × ២) ឬ (ប + ទ) × ២ ។

គេបង្ហាញឲ្យសិស្សឃើញច្បាស់យ៉ាងនេះ រួចគេនាំឲ្យរកមូលវិធានហើយឲ្យហាត់រកបរិវេណក្នុងការដ្ឋាន ។

ខ – រកផ្ទៃ ។ គេធ្វើឲ្យសិស្សឃើញថា ក្នុងមួយស្រទាប់ក្រោមមាន ៥ ម. ក្រឡា ក្នុងផ្ទៃតាំងមូលមាន ៣ ស្រទាប់គឺ ៥ ម. ក្រឡា បីដង ត្រូវជា ១៥ ម. ក្រឡា ។ គេយកបណ្ដោយមកគុណនឹងទទឹង គឺ ប. × ទ. ឬ ១ ម$^២$ × ៥ × ៣ = ១៥ ម$^២$ ។

គ– រកបណ្ដោយ ។ គេយកផ្ទៃមកចែកនឹងទទឹង គឺ $\frac{ផ}{ទ}$ ឬ $\frac{១៥}{៣}$ = ៥ ម. ។

ឃ– រកទទឹង ។ គេយកផ្ទៃមកចែកនឹងបណ្ដោយ គឺ $\frac{ផ}{ប}$ ឬ $\frac{១៥}{៥}$ = ៣ ម. ។

## របៀបបង្រៀនវត្ថុស្ហាញ្ញាយន៍

ដែលហៅថាវត្ថុស្ហាញ្ញាយន៍ គឺគេយកវត្ថុអ្វីមួយមកបង្រៀនសិស្សៗ បើគ្មានវត្ថុទេ គេមិនអាចនឹងបង្រៀនបានឡើយ ។ ហេតុដូច្នេះ មុននឹងបង្រៀនវត្ថុស្ហាញ្ញាយន៍ គេត្រូវប្រមូល មុនពេលចូលរៀន នូវវត្ថុដែល

ត្រូវបង្រៀន ព្រមទាំងរបស់អ្វីដែលគេត្រូវការប្រើក្នុងពេលបង្រៀននោះៗ

ឧបមា ដូចជាបង្រៀនអំពីអំបិល គេត្រូវរកអំបិលគ្រប់មុខ ទឹកត្រី ស្លាបព្រាដែក ទៀន ឈើគូស ។ល។

១_ នាំសិស្សពិនិត្យ :

ក– ដឹងភ្នែក : សិស្សអាចឃើញរាង ពណ៌របស់វត្ថុនោះៗ

ខ – ដឹងដៃ : សិស្សអាចដឹងថាវត្ថុនោះ រឹង ទន់ រលើង គគ្រាត ក្ដៅ ឬ ត្រជាក់ ។

គ – ដឹងច្រមុះ : សិស្សអាចដឹងក្លិនវត្ថុនោះ ៗ មានវត្ថុខ្លះ ដែលគេសំគាល់បានដោយអាស្រ័យនឹងច្រមុះ ដូចជាប្រេងកាត ប្រេងសាំង ទឹកត្រី ។ល។

ឃ– ដឹងអណ្ដាត : សិស្សអាចដឹងថា វត្ថុនោះមានជាតិ ផ្អែម ជូរ ប្រៃ ល្វីង ចត់ ។ល។

ង– ដឹងត្រចៀក : សិស្សអាចដឹងថា វត្ថុនោះមានសូរយ៉ាងនេះ វត្ថុនោះមានសូរយ៉ាងនោះ ៗ លោហធាតុនីមួយ ៗ មានសូរទីទៃ ៗ ពីគ្នា ។

សូមកុំភ្លេចថា គេមិនប្រើវិញ្ញាណទាំង ៥ នេះ បំពោះទៅលើវត្ថុទាំងអស់ទេ គេមានរំលងខ្លះដែរ ។ ដូចជាបង្រៀនអំពី

អំបិល គេមិនត្រូវប្រើប្រមុះទេ បង្រៀនអំពីប្រេងកាត គេមិនត្រូវប្រើត្រចៀកទេ ។ល។

២– នាំសិស្សធ្វើការពិសោធន៍ ដែលគួរធ្វើបាននឹងវត្ថុដែលគេយកមកបង្រៀននោះ ។

ឧបមា ដូចជាអំពីអំបិល បើគេដាក់អំបិលទៅក្នុងទឹក អំបិលនោះរលាយ ។ បើគេយកទឹកនេះមកភ្លក់ គេដឹងថាទឹកនេះប្រៃ ពីព្រោះក្នុងទឹកនេះមានជាតិអំបិល ដូចជាទឹកសមុទ្រ ។ បើគេយកទឹកប្រៃនេះទៅរំងាស់ គេឃើញនៅសល់អំបិល ។ល។

៣– នាំសិស្សឲ្យរកប្រយោជន៍នៃវត្ថុនោះ ។

៤– ឲ្យមេរៀនសង្ខេប ។

គេនាំសិស្សឲ្យពិនិត្យ ដូចបានពណ៌នាខាងលើនេះ ហើយបើគេសរសេរនៅលើក្ដារខៀនបញ្ជរ ចម្លើយណាសំខាន់ៗ របស់សិស្ស ដើម្បីទុកធ្វើជាមេរៀនសង្ខេបនោះ ជាការប្រសើរណាស់ ។

## របៀបបង្រៀនចរិយាសាស្ត្រ

គេបង្រៀនចរិយាសាស្ត្រ បានពីរយ៉ាង :

ក– យ៉ាងគឺក្នុងថ្ងៃណា ពេលណា នៅកន្លែងណាក៏បាន ។ បើ

គេឃើញសិស្សណា ក្មេងណា មនុស្សណា ប្រព្រឹត្តអ្វី គេសួរពិចារណា ចំពោះទៅសិស្សរបស់គេថា៖ សិស្សនោះ ក្មេងនោះ អ្នកនោះ បានប្រព្រឹត្តអ្វី ។ ការប្រព្រឹត្តនោះប្រសើរ ឬខុសឆ្គងពីគន្លងធម៌ ។ល។

គេទូន្មានសិស្សរបស់គេ ឲ្យយកតម្រាប់តាម ត្រង់ណាដែលត្រូវ ឲ្យវៀសវាងការប្រព្រឹត្តត្រង់ណាដែលខុស ។

១– ម្យ៉ាងទៀត គេនិទានរឿងខ្លីៗដែលគេតែងខ្លួនគេ ឬគេដកយកពីគម្ពីរសៀវភៅ ឲ្យសិស្សទាំងអស់គ្នាស្តាប់ ឲ្យវានិយាយឡើងវិញ ។ គេសួរពិចារណាក្នុងរឿងនោះ តើអ្នកនោះ សត្វនោះ ប្រព្រឹត្តយ៉ាងម្តេច?។ គេទូន្មានសិស្សឲ្យយកតម្រាប់ណាដែលត្រូវ ឲ្យវៀសវាងទង្វើអំពើណាដែលពុំគប្បី ។ ជួនណាគេទាញយកពាក្យបុរាណមកបន្ថែមលើសេចក្តីទូន្មាននោះ ។

លុះធ្វើយ៉ាងនេះរួចស្រេចហើយ គេដាក់មេរៀនខ្លីៗឲ្យសិស្សចម្លង ។

## របៀបបង្រៀនអនាម័យ

គេបង្រៀនអនាម័យ ដូចជាគេបង្រៀនចរិយាសាស្ត្រដែរ ។ តែចំពោះអនាម័យ គេត្រូវធ្វើការពិសោធន៍ឲ្យសិស្សឃើញ ។

ឧបមា ដូចជាគេទូន្មានសិស្សថា “ អ្នកត្រូវដុះលាងដៃនឹងសាប៊ូ

មុនពេលបរិភោគ ព្រោះសាប៊ូនេះអាចកាត់ក្អែលបាន” ។ គេត្រូវយកទឹក ហើយទិញសាប៊ូមកដុះលាងដៃឲ្យសិស្សឃើញ ។

## របៀបបង្រៀនភូមិសាស្ត្រ

ដើម្បីនឹងបង្រៀនអំពីភូមិសាស្ត្រ គេចាប់ពីកន្លែងដែលនៅជិតសិស្ស គឺអំពីកន្លែងរៀន ។ គេនាំសិស្សឲ្យពិនិត្យផែនទី កន្លែងរៀន ដែលគេគូរនៅលើក្ដារខៀនបញ្ឈរ ឲ្យវាឃើញថា ទិសឯកើតនៅខាងស្ដាំ, ទិសឯលិចនៅខាងឆ្វេង, ទិសឯជើងនៅខាងលើ, ទិសឯត្បូងនៅខាងក្រោម របស់នេះនៅត្រង់នេះ របស់នោះនៅត្រង់នោះ ។ល។

ផុតបង្រៀនអំពីសាលារៀន ភូមិ ឃុំ ។ល។ គេធ្វើដូចជាបង្រៀនអំពីកន្លែងរៀនដែរ ។ ក្រៅអំពីស្ទឹង ទន្លេ បឹង ភ្នំ ផ្លូវកាន់គ្នាទៅវិញទៅមក ។ល។ គេនាំសិស្សឲ្យសង្កេតអំពីបណ្ដាជន របររកស៊ីរបស់អ្នកស្រុក មន្ត្រីក្នុងឃុំ ។ល។

ដើម្បីនឹងបង្រៀនភូមិសាស្ត្រ អំពីស្រុក ខេត្ត ប្រទេស ។ល។ គេថ្លែងឲ្យសិស្សស្ដាប់ គេបង្ហាញព្រំប្រទល់ ភ្នំ ស្ទឹង ផ្លូវ ។ល។ នៅលើផែនទី ។ បើគេគូរនៅលើក្ដារខៀនបញ្ឈរ ផែនទីខេត្ត ប្រទេស ។ល។ ឲ្យសិស្សមើល នោះជាការល្អណាស់ ។

ផុតទៅពេល ដែលគេសួរបញ្ហាក្នុងមេរៀនចាស់ គេឲ្យសិស្ស

គូរផែនទី នៅលើក្ដារខៀនបញ្ឈរ ។

## របៀបបង្រៀនពង្សាវតារ

គេយករឿងព្រេង ឬរឿងដែលមានក្នុងសៀវភៅ មកនិទានមួយៗ វគ្គម្ដងៗ ឲ្យសិស្សស្ដាប់ ឲ្យគេនិយាយរឿងនោះឡើងវិញ ។ គេពន្យល់ពាក្យពិបាកៗ គេសួរបញ្ជាក់ជារឿយៗ គេបង្ហាញទីកន្លែងនៅក្នុងផែនទី គេត្រាគោលមេរៀននៅលើក្ដារខៀនបញ្ឈរ ព្រមទាំងនាមស្ដេច និងសករាជ ។

## របៀបបង្រៀនលោកនីតិ

គេនាំសិស្សឲ្យសង្កេតអំពីករណីយកិច្ចរបស់រាស្ត្រ និងមុខក្រសួងរបស់មន្ត្រីឃុំ ស្រុក ខេត្ត ។ នៅក្នុងសាលារៀន សិស្សមានករណីយកិច្ចដូចជាអ្នកស្រុកក្នុងឃុំដែរ មានច្បាប់ដែលត្រូវប្រតិបត្តិដែរ ។

គ្រូខ្លះមានគំនិតឲ្យសិស្សបោះឆ្នោតរើសគ្នាធ្វើជាសមាជិក ដែលត្រូវបញ្ចូលទៅក្នុងគណៈកម្មាធិការមួយ ដើម្បីតុបតែងច្បាប់សម្រាប់សាលារៀន បញ្ចូលទៅក្នុងគណៈកម្មាធិការ សម្រាប់កាត់ទោសនៃសិស្សណាដែលល្មើសបញ្ញត្តិរបស់សាលា ។ ឯគ្រូត្រូវចាំមើលការខុសត្រូវ ។ ធ្វើយ៉ាងនេះជាការប្រសើរដែរ ។

## របៀបបង្រៀននៅកណ្ដាលវាល

គេមិនបង្រៀនតែក្នុងកន្លែងរៀនជានិច្ចទេ ។ ជួនកាលគេនាំសិស្សចេញទៅក្នុងផ្សារ សាលា ក្នុងភូមិ ។ គេនាំដើរលេងផង ហើយគេបង្រៀនផង ។ តាមភាសាបារាំង គេហៅថា " ក្លាស្ស៍ប្រូមើណាដ " គឺ " បង្រៀន – ដើរលេង " ។ ពាក្យនេះដូចជាមិនសូវពីរោះនឹងស្ដាប់ គួរយើងសន្មតហៅថា " បង្រៀននៅកណ្ដាលវាល " ។ គ្រូមួយៗ គួរនាំសិស្សចេញពីកន្លែងរៀន បើយ៉ាងហោច ១ ខែម្ដង ក្នុងព្រឹកថ្ងៃពុធ ឬថ្ងៃសៅរ៍ ឆ្ពោះទៅកន្លែងណាមួយដែលបានពិនិត្យជាមុនរួចមកហើយ ដើម្បីនឹងបង្រៀនវិជ្ជាដូចមានតទៅ :

**វិធីហាត់ប្រាណ :** ក្នុងពេលដែលដើរនេះសិស្សត្រូវប្រើកម្លាំងកាយ ដូចក្នុងពេលគេបង្រៀនវិធីហាត់ប្រាណ ។

**របៀបមាត្រាម៉ែត្រ :** សិស្សចេញពីកន្លែងទៅ ពីម៉ោងប៉ុណ្ណោះ ទៅដល់កន្លែងនោះម៉ោងប៉ុណ្ណោះ វាដើរបានប៉ុណ្ណោះគីឡូម៉ែត្រ ក្នុងរវាង ប៉ុណ្ណោះមីនុត – ម៉ោង ។ សិស្សឃើញថា ១ គីឡូម៉ែត្រ គឺប្រវែងពីត្រង់នេះទៅត្រង់នោះ វាឃើញថា វាដើរអស់រយៈប៉ុណ្ណោះមីនុត ។

**ភូមិសាស្ត្រ :** គេសួរសិស្សថា ផ្លូវនេះមកពីកន្លែងណា ទៅដល់

កន្លែងណា កាត់ភូមិណាខ្លះ ឆ្លងស្ទឹងអ្វី ៗ ស្ទឹងនេះទឹកយ៉ាងម្ដេច មាននាវាទៅមកបានឬទេ ចុះមកពីភ្នំណា ហូរធ្លាក់ទៅត្រង់ណា ៗ ល ៗ

លោកនីតិ : សិស្សត្រូវដឹងថា អ្នកថ្មើរជើងត្រូវដើរខាងណាថ្នល់ មុននឹងឆ្លងថ្នល់ត្រូវធ្វើម្ដេចខ្លះ ៗ

ចរិយាសាស្ត្រ : បើសិស្សដើរទៅប្រទះនឹងចាស់ព្រឹទ្ធាចារ្យ នាម៉ឺនតូច - ធំ ក៏ត្រូវធ្វើម្ដេច ៗ

ពាក្យនិងភាសា : ក្នុងពេលដែលដើរនេះ សិស្សមានឱកាសច្រើនណាស់ នឹងរៀនពាក្យហើយនឹងភាសា ៗ

អនាម័យ : ដល់ភូមិនីមួយ ៗ គេបង្ហាញសិស្សឲ្យឃើញថា គេសំអាតក្រោមផ្ទះយ៉ាងដូចម្ដេច គេប្រមូលសំរាមទៅចោលត្រង់ណា ៗល ៗ

ពង្សាវតារ : កន្លែងនេះ វត្តនេះឈ្មោះអ្វី ហេតុអ្វីបានជាគេដាក់ឈ្មោះយ៉ាងនេះ ៗ ល ៗ ស្ដេចណាសាងប្រាសាទនេះ ៗ

តែងសេចក្ដី : លុះសិស្សត្រឡប់មកដល់កន្លែងរៀនវិញ គេនាំក៏ឲ្យពណ៌នាអំពីដំណើរដែលក៏ទើបនឹងធ្វើនោះ ៗ

## ការរៀបចំវិធីបង្រៀន

គេត្រូវគិតរៀបចំនឹងបង្រៀន រាល់ថ្ងៃ មុនពេលចូលរៀន ៗ

ក) គេគិតរក តើថ្ងៃនេះគេបង្រៀនអំពីអ្វីខ្លះ ។

ខ) គេប្រមូលប្រដាប់ប្រដា ដែលត្រូវយកមកបង្រៀន ។

គ) គេសរសេរសេចក្តីដែលរៀបចំនេះ ដាក់ក្នុងសៀវភៅមួយ ។ ក្នុងមេរៀនទីមួយ ៗ គេចុះរឿងដែលត្រូវបង្រៀន គោលនៃមេរៀននោះ ព្រមទាំងពាក្យពន្យល់ និងពាក្យសួរ ។ គេសរសេរមេរៀនសង្ខេប ឬការហាត់សរសេរក្នុងសៀវភៅរបស់គេ ឬគេចង្អុលទៅរកសៀវភៅណា ដែលគេស្រង់មេរៀនសង្ខេប ឬការហាត់សរសេរនោះ ។

នៅថ្នាក់ខ្ពស់ ៗ ពេលទីមួយ ៗ ដែលត្រូវបង្រៀននព្វន្ត របៀបមាត្រាម៉ែត្រ រេខាគណិតសាស្ត្រ គួរចែកដូចមានតទៅ :

១– ការហាត់គិតរកនឹងប្រាជ្ញា ។

២– កែការហាត់ដែលឲ្យធ្វើពីថ្ងៃមុន ។

៣– សួរបញ្ជាក់ក្នុងមេរៀនពីថ្ងៃមុន ។

៤– មេរៀនក្នុងថ្ងៃនេះ ។

៥– ការហាត់សរសេរ ។

## អំពីសៀវភៅសរសេររបស់សិស្ស

សិស្សទីមួយ ៗ ត្រូវមានសៀវភៅស្តើងមួយសម្រាប់សរសេរការ.

ហាត់គ្រប់មុខ រាល់ថ្ងៃ ។

កូនថ្នាក់នីមួយ ៗ ចាប់តាំងពីថ្នាក់បរិវត្តណាបានទៅ ត្រូវឲ្យមាន សៀវភៅក្រាស់មួយ សម្រាប់ឲ្យសិស្សសរសេរម្នាក់ ១ ថ្ងៃ កិច្ចការទាំង ប៉ុន្មានក្នុងកន្លែងរៀន ។ សៀវភៅនេះ បើសិស្សសរសេរអស់ទំព័រ ហើយ ត្រូវតម្កល់ទុកក្នុងកន្លែងរៀន ។

គ្រូបង្រៀនហើយនឹងចាងហ្វាងសាលា ត្រូវជំនុំគ្នា ដើម្បីនឹងសម្រេច អំពីសៀវភៅឯទៀត ដូចជាសៀវភៅសរសេរអក្សរផ្ចង់ គំនូរ មេទន្ទេញ តែងសេចក្តី មេរៀន ។ល។

# ដំណឹងសៀវភៅថ្មី

ផ្សាយចេញពីបណ្ណាគារ ប៊ុត-ឆាង ក្នុងពេលប[illegible]នេះ

១ – គណិតសម្រាំងទី - ២ , ៣ , ៤

២ – របៀបរៀនគន់គ្រួសយ៉ាងឆាប់

៣ – ប្រស្នានព្វន្ត ថ្នាក់មធ្យមដ្ឋាន - ឧត្តមដ្ឋាន

៤ – ភាសាបដិវត្តន៍ ( ខ្មែរប្រែជាបារាំង )

៥ – វិធីប្រើវណ្ណយុត្តិនិងវណ្ណសញ្ញា

៦ – អក្សរចល័តខ្មែរទំនើបថ្មី ( សម្រាប់គ្រូ )

៧ – ការបាត់ថ្នាក់ខ្មែរ-បារាំង ( សម្រាប់គ្រូ )

៨ – អក្ខរានុក្រមខ្មែរ ( កម្រាស់ ២០០០ ទំព័រមានក្រប, និងផ្សាយលក់ក្នុងខែសីហានេះ )

តម្លៃ ១៥.០០